# ដែនដីពុទ្ធភូមិ



រៀបរៀងដោយ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ ភែច ទិមុត្ត

៥០០០ឆ្នាំ
WWW.5000-YEARS.ORG



ឯកសារនេះ បានទាញចេញពី
៥០០០ឆ្នាំ.ORG

## ប្រទេសឥណ្ឌា

សាធារណរដ្ឋឥណ្ឌា ស្ថិតនៅអាស៊ីទ្វីបភាគខាងត្បូង ជាប្រទេសដែលមានព្រំប្រទល់ខាងជើងជាប់នឹងចិន នេប៉ាល់ ប៊ុយតាន់ ខាងត្បូងជាប់មហាសមុទ្រឥណ្ឌា ខាងកើតជាប់ប្រទេស បង់ក្លាដែស និង ភូមា ខាងលិចជាប់សមុទ្រអារ៉ាប់ និងប៉ាគីស្ថាន មានផ្ទៃដី ៣.១៦៥.៥៩៦ គ.ម.ក្រឡា មានប្រជាជនជាង មួយពាន់ម្ភៃប្រាំពីរលាននាក់ ក្នុងឆ្នាំ ២00១ ។ ប្រកបមុខរបរកសិកម្ម ៦៣% មាន២៨រដ្ឋ ទីក្រុងធំឈ្មោះញូវដែលី ។ មានផ្លូវជាតិ ២លានគ.ម. រាយពេញប្រទេស ផ្លូវដែក ៦២.៨0៩ គ.ម. ផ្លូវទឹក ១៩.១៤៥ គ.ម.។ ធ្វើដំណើរដោយយន្តហោះពីស្រុកខ្មែរត្រូវចំណាយពេល ៦ម៉ោង ទើបដល់ញូដេលី។ ប្រជាជនកាន់សាសនា ហិណ្ឌូ ៨៣%, មូស្លីម១១%, គ្រីស្ត២%, ស៊ីក២%, ព្រះពុទ្ធ ១%, និង មានសាសនាដទៃជាច្រើនទៀត... ។

## ប្រទេសនេប៉ាល់

ប្រទេសនេប៉ាល់នៅក្នុងអាស៊ីទ្វីបភាគខាងត្បូង មានផ្ទៃដី ១៤៧.១៨១ គ.ម.ក្រឡា មានប្រជាជន២៩លាននាក់ ។ មានព្រំប្រទល់ខាងជើងជាប់នឹងប្រទេសចិន ខាងលិច ខាងកើត ខាងត្បូងជាប់ប្រទេសឥណ្ឌា មានទីក្រុងធំឈ្មោះ កដ្ឋមណ្ឌូ ។ ប្រជាជនកាន់សាសនាហិណ្ឌូ៨៦%, ព្រះពុទ្ធសាសនា ៨%, មូស្លីម ៤%, គ្រីស្ត 0.២%, ចែន 0.១% និង ផ្សេងៗ ២% ។

# ឧទ្យានលុម្ពិនី


រូបគំនូរព្រះអង្គប្រសូត


ក្នុងអាគារ កន្លែងប្រសូត


ប្រអប់សំរាប់បូជាគ្រឿងសក្ការៈផ្សេងៗ


រូបបដិមាព្រះអង្គប្រសូតពីបុរាណ

លុម្ពិនីសព្វថ្ងៃហៅក្លាយជារុម្មិណ្ឌេនៅក្នុងប្រទេសនេប៉ាល់មានចម្ងាយ ២៩៣គ.ម. ពីទីក្រុង កដ្ឋមណ្ឌូ (នេប៉ាល់) នៅខាងទិសឦសាននៃក្រុង ពារាណសី នៅទិសពាយព្យ នៃនគរកុសិនារា។ ពុទ្ធស្ថានទី១ ជាកន្លែងដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រសូតចាកព្រះគភ៌នៃព្រះបរមមាតា គឺព្រះនាង សិរិមហាមាយាទេវី។ កាលព្រះបរមពោធិសត្វបំពេញបារមីគ្រប់ ៤អសង្ខេយ្យ និងមួយសែនផែនដី ហើយបន្ទាប់អំពីទេវតាហ្មឺនចក្រវាលសូមអារាធនាព្រះពោធិសត្វ។ ព្រះពោធិសត្វពិចារណាមើល មហាវិលោកនៈទាំង៥ ទើបចុតិចាកតុសិតពិភព ចាប់បដិសន្ធិក្នុងព្រះគភ៌ព្រះនាង សិរិមហាមាយាទេវី ជាអគ្គមហេសីរបស់ព្រះបាទ សុទ្ធោទនៈ ក្នុងនគរ កបិលពស្តុបុរី ក្នុងថ្ងៃព្រហស្បតិ៍ ១៥កើត ខែអាសាឍ ឆ្នាំរកា កាលនោះផែនដីកក្រើកញាប់ញ័រ ដោយការចុះចាប់បដិសន្ធិ របស់ព្រះបរមពោធិសត្វ ។ ព្រះនាង សិរិមហាមាយាទេវី ទ្រទ្រង់គភ៌អស់ ១០ខែ ដោយមានស្តេចមហារាជទាំង ៤ តាមជួយថែរក្សា។


ពុទ្ធបរិស័ទយើងបានថតរូបនៅជិតសសរស្តម្ភ

# ឧទ្យានលុម្ពិនី










កាលព្រះ**ពោធិសត្វ** នៅក្នុងគភ៌នៃព្រះវរមាតា ១០ ខែ ព្រះនាង **សិរិ-មហាមាយាទេវី** សុំអនុញ្ញាតពីព្រះបាទ **សិរិសុទ្ធោទនៈ** ដើម្បីយាងទៅសួរសុខទុក្ខព្រះញាតិនៅឯនគរ**ទេវទហៈ** ។ ព្រះនាងយាងដល់ពាក់កណ្ដាលផ្លូវគឺឧទ្យានលុម្ពិនីនេះ កាលនោះឧទ្យាននេះ បរិបូរណ៍ដោយសម្រស់ស្រស់ត្រកាលគួរជាទីរីករាយ ។ ទើបព្រះនាងយាងចុះពី **សុវណ្ណសិវិកាភាជ** ហើយបានទតឧទ្យានលុម្ពិនីនេះ ដោយព្រះទ័យសោមនស្ស ។ ក្នុងកាលនោះ ព្រះគភ៌ក៏បានកម្រើកឡើង ព្រះបរមពោធិសត្វ ក៏ប្រសូតចាកព្រះគភ៌នៃព្រះវរមាតា ដូចជាព្រះធម្មកថិកចុះចាកគ្រែធម្មាសនៈ ។

ផែនដីក៏កក្រើកញាប់ញ័រ ពួកទេវតាហ្មឺនចក្រវាលបានជួបជុំគ្នាក្នុងឧទ្យានលុម្ពិនីនេះ មហាព្រហ្មទទួលព្រះបរមពោធិសត្វដោយស្បៃមាស ទេវតា

បានទទួលពីដៃមហាព្រហ្ម បន្តមកទៀត មនុស្សទទួលពីទេវតា ព្រះពោធិសត្វយាង ៧ជំហាន ទៅទិសឧត្តរ ហើយពោលនូវ អភិសវាចាថា :



នមស្ការកន្លែងព្រះអង្គប្រសូត

**អគ្គោហមស្មិ** **លោកស្ស**

**ជេដ្ឋោហមស្មិ** **លោកស្ស**

**សេដ្ឋោហមស្មិ** **លោកស្ស**

**អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោ**



អាគារគ្របពីលើចេតិយចាស់ ( ជប៉ុនកសាង)

- យើងជា អគ្គបុគ្គល ក្នុងលោក
- យើងជា បុគ្គល ដ៏ចម្បងក្នុងលោក
- យើងជា បុគ្គល ដ៏ប្រសើរក្នុងលោក
- ជាតិនេះជាជាតិចុងក្រោយរបស់យើង ជាតិថ្មីទៀតមិនមានឡើយ ។



និមន្ត និងធ្វើដំណើរចូលទៅកន្លែងប្រសូត

ព្រះអង្គប្រសូតក្នុងថ្ងៃសុក្រ ១៥កើត ខែពិសាខ ឆ្នាំច ថ្ងៃព្រះអង្គប្រសូតមាន



# ឧទ្យានលុម្ពិនី





ពុទ្ធបរិស័ទទាំងពួងស្គាល់ថា ទីនេះជា ឧទ្យានលុម្ពិនី កន្លែង ព្រះអង្គប្រសូត ព្រោះមាន សសរស្តម្ភ មួយ ដែលព្រះរាជាព្រះនាម ព្រះបាទ **ធម្មាសោក** បាន កសាងឡើង ក្នុងចន្លោះព.ស.២០០ ទៅ ៣០០ ដើម្បី ចំណាំថា ទីនេះជា កន្លែងប្រសូត ។

ប្រទីបសន្តិភាពមិនដែលរលត់តាំងពីឆ្នាំ ១៩៨៨ កសាងដោយ ជប៉ុន ក្នុងលុម្ពិនី





ឧបាសិកា **ទិ យន** (ស្លាប់) ម្តាយលោកគ្រូ ធម្មាចារ្យ **កែវ វិមុត្ត**

# វត្តខ្មែរលុម្ពិនី ប្រទេសនេប៉ាល់






ខ្លោងទ្វារវត្តខ្មែរលុម្ពិនី កសាងអស់ ៦ម៉ឺនដុល្លារ

ព្រះសង្ឃខ្មែរមានព្រះទេវសត្ថា **ពៀយ មេត្តា** ជាប្រធានសមណនិស្សិតខ្មែរ នៅប្រទេសឥណ្ឌា បានដឹកនាំពុទ្ធបរិស័ទកសាងវត្តខ្មែរលុម្ពិនី នៅប្រទេសនេប៉ាល់ វត្តខ្មែរពុទ្ធគយា វត្តខ្មែរ វេសាលី និងវត្តខ្មែរកុសិនារា ដើម្បីជាប្រយោជន៍ដល់សមណនិស្សិត និងគណៈធម្មយាត្រាមកកាន់ដែនដីពុទ្ធភូមិ ។



ព្រះភិក្ខុ ពៀយ មេត្តា



ពុទ្ធបរិស័ទប្រគេនចង្ហាន់ព្រះសង្ឃ







កំពុងកសាងព្រះវិហារ



# នគរកបិលពស្ដុ នេប៉ាល់

ខ្លោងទ្វារព្រះអង្គចេញបួស

នគរកបិលពស្ដុ ជានគរសក្យវង្សខាង ពុទ្ធបិតា សព្វថ្ងៃនៅនេប៉ាល់ ព្រះ**បរមពោធិសត្វ**ទ្រង់ចុះចាប់បដិសន្ធិ និង ទ្រង់ចម្រើនវ័យវឌ្ឍនាក្នុងនគរនេះ។

ក្នុងនគរនេះផងដែរ ព្រះអង្គបានរាជាភិសេកជាមួយព្រះនាង **យសោធរាពិម្ពា**ក្នុងព្រះជន្ម ១៦ ឆ្នាំ សោយសុខក្នុងមហាប្រាសាទ៣ សមនឹងរដូវទាំងបី កាលបារមីគ្រប់គ្រាន់ហើយ ក្នុងព្រះជន្ម ២៩វស្សា ទើបទ្រង់យាងចេញសាងព្រះផ្នួស ក្នុងថ្ងៃដែលព្រះ **រាហុល**ប្រសូត។



ស្រះបោក្ខរណីក្នុងរាជវាំង



ខ្លោងទ្វារទិសខាងកើតនៃនគរកបិល-ពស្ដុ ព្រះអង្គយាងសាងព្រះផ្នួសចេញតាមខ្លោងទ្វារនេះ ←



ផ្ទៃរាជវាំងចាស់នៃនគរកបិលពស្ដុ

# ព្រះស្តូបពុទ្ធមាតា និង ពុទ្ធបិតា










ព្រះ ពោធិសត្វ ប្រសូតបាន ៧ថ្ងៃ ព្រះមាតា សោយទិវង្គត ។ ព្រះអង្គទ្រង់ត្រាស់ដឹងនូវ សព្វញ្ញុតញ្ញាណទ្រង់សម្តែងព្រះធម៌ ប្រោសពួក ព្រះញាតិ ។ ព្រះបិតាបានសម្រេចជាព្រះ អរហត្ត ក៏បរិនិព្វាន ព្រះពុទ្ធជាម្ចាស់ បានរៀបចំបូជាសព ព្រះបិតា បានកសាងព្រះចេតិយ២ ទន្ទឹមគ្នា នៅ ទិសឦសាននៃព្រះនគរ ប្រហែលជាង ២០០- ម៉ែត្រ តម្កល់ធាតុ ព្រះមាតា ព្រះបិតា នៅក្បែរ នគរកបិលពស្តុ គួរឱ្យជ្រះថ្លា និងតក់ស្លុតខ្លាំងពន់ ពេក ។



ប្រទក្សិណព្រះចេតិយទាំងពីរ

# គំនូរពុទ្ធប្បវត្តិបញ្ជាក់នៅក្នុងគនរកបិលពស្តុ






(ទ្រង់ចុះចាប់បដិសន្ធិ) (ទ្រង់ប្រសូត) (ព្រាហ្មណ៍ទាំង៨ទាយលក្ខណៈព្រះអង្គ) (៧ឆ្នាំបានបឋមឈាន)






(ទ្រង់សម្តែងសិល្បៈវិជ្ជាបាញ់ធ្នូអស្ចារ្យក្រៃ ឱ្យពួកព្រះញាតិបានឃើញ) (ព្រះជន្ម១៦ទ្រង់រៀបអភិសេកជាមួយព្រះនាងពិម្ពា)






(ទ្រង់ទតទេវៈនិមិត៤គឺ ចាស់ ឈឺ ស្លាប់ អ្នកបួស) (ព្រះជន្ម២៩ មានព្រះទ័យនឿយណាយទ្រង់យាងចេញបួសក្នុងកណ្តាលរាត្រី)






ទ្រង់កាត់ព្រះកេសា(ផ្នួស) (ពិម្ពាស្តាប់ធម៌) (ពិម្ពាឱ្យរាហុលសុំកំណប់ទ្រព្យ) (ព្រះពុទ្ធបិតាទ្រង់ប្រឈួន)

# កន្លែងព្រះពុទ្ធកក្កុសន្ធោប្រសូត


នមស្ការ និងស្ដាប់ធម៌



ជិះឡានទៅកន្លែងព្រះកក្កុសន្ធោប្រសូត


សសរស្តម្ភថ្ម(បានបាក់បែក)



កន្លែងព្រះពុទ្ធ កក្កុសន្ធោ ប្រសូតនៅខាងលិចវត្ត និគ្រោធារាម ប្រហែល ៣គីឡូម៉ែត្រ ទីនេះក៏មានសសរស្តម្ភមួយ ដែលព្រះបាទធម្មាសោកបានកសាងដើម្បីចំណាំទុក តែឥឡូវបានបាក់ពាក់កណ្ដាលទៅហើយ។ សូមជ្រាបថា ព្រះពុទ្ធកក្កុសន្ធោជាព្រះពុទ្ធអង្គទីមួយ ក្នុងភទ្ទកប្បនេះ មានព្រះជន្ម ៤ម៉ឺនឆ្នាំ។ សម័យនោះ ព្រះពោធិសត្វនៃយើងបានកើតជាស្ដេចព្រះនាមថា ខេមៈ ទ្រង់បានធ្វើទានដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធកក្កុសន្ធោជាប្រធាន ព្រះរាជាស្ដាប់ធម្មកថា មានសេចក្ដីជ្រះថ្លា បានលះរាជសម្បត្តិបួសជាភិក្ខុ ព្រះកក្កុសន្ធោអរហន្តសម្មាសម្ពុទ្ធ បានព្យាករព្រះអង្គថា នឹងបានត្រាស់ដឹង ជាព្រះពុទ្ធ។



# កន្លែងព្រះសម្មាសម្ពុទ្ធកោនាគមនោប្រសូត

ទីនេះគឺជាកន្លែងព្រះសម្មាសម្ពុទ្ធ **កោនាគមនោ** ប្រសូត ហើយទីនេះដែរស្ថិតមិនឆ្ងាយពីនគរកបិលពស្តុប៉ុន្មានទេ ។ ព្រះបាទ ធម្មាសោក បានបន្សល់ទុកសសរស្តម្ភមួយដែរ បច្ចុប្បន្នសសរនេះ បានដួលដេកទៅហើយ ។



បដិមាព្រះពុទ្ធកោនាគមនោ

ផ្ទះតូចមួយគ្របពីលើសសរស្តម្ភ





សសរស្តម្ភបានដួលដេកទៅហើយ



ស្រះទឹកនៅជិតសសរស្តម្ភ

ព្រះពុទ្ធ កោនាគមនោ មានព្រះជន្ម ៣ ម៉ឺនឆ្នាំ កាលនោះ ព្រះពោធិសត្វនៃយើងបានកើតជាស្តេចនៅនគរមិថិលា ព្រះនាមថា **បព្វតរាជ** ដោយមានសេចក្តីជ្រះថ្លានឹងព្រះពុទ្ធ ហើយបានធ្វើទាននិងបួសជាភិក្ខុ ព្រះសម្មាសម្ពុទ្ធកោនាគមនោ ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ។

(ទីនេះនៅនេប៉ាល់)

**ទីនេះមានសសរស្តម្ភ និង ព្រះពុទ្ធបដិមា**



សសរស្តម្ភដួលដេក

# វត្តនិគ្រោធារាម



វត្តនេះ កសាងបូជាចំពោះព្រះរតនត្រ័យ ដោយសក្យវង្ស។ វត្តនិគ្រោធារាម ជាកន្លែងព្រះរាហុលបួសជាសាមណេរមុនគេក្នុងសាសនា និងព្រះនន្ទសាងផ្នួសផងដែរ។



ខឿនវិហារវត្តនិគ្រោធារាម

ព្រះបរមសាស្តា មួយអន្លើដោយ ព្រះអរហន្ត ២ ហ្មឺន គង់នៅជាដំបូង កាលដែលព្រះអង្គទ្រង់យាងពីនគររាជគ្រឹះទៅប្រោសព្រះញាតិ ទ្រង់ត្រាស់សម្តែងនូវវេស្សន្តរជាតកក្តី នូវពុទ្ធវង្សក្តី និងព្រះពុទ្ធអង្គ គង់ចាំវស្សាទី១៥ ក្នុងវត្តនិគ្រោធារាមនេះឯង។ សព្វថ្ងៃវត្តនិគ្រោធារាមនេះ នៅក្នុងដែនដីប្រទេស នេប៉ាល់ សល់នៅត្រឹមតែខឿនបន្តិចបន្តួចតែប៉ុណ្ណោះ។



ព្រះរាហុលបួសជាសាមណេរ

**សព្វេ ធម្មា អនត្តា**

ធម៌ទាំងពួងមិនមែនជារបស់ខ្លួន





# ស្ទឹងរោហិណី


ស្ទឹងរោហិណី-នេប៉ាល់



នៅចន្លោះនគរកបិលពស្តុ និងនគរទេវទហៈ ។ សព្វថ្ងៃ ធ្វើដំណើរទៅថ្វាយបង្គំនូវព្រះស្តូបរាមគ្រាម ក៏បានឆ្លងកាត់ស្ទឹងរោហិណីនេះដែរ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងនូវ អត្ត-ទណ្ឌសូត្រ និង ព្រះជាតកយ៉ាងច្រើនផ្សះផ្សាពួកព្រះញាតិទាំងពីរនគរ អំពីរឿងដណ្តើមទឹកស្ទឹងនេះធ្វើស្រែ ។ ព្រះអានន្ទត្ថេរ ក៏បរិនិព្វាននៅឰដ៏អាកាសលើស្ទឹងរោហិណី ក្នុងកាលនោះពួកព្រះញាតិក្នុងនគរទាំងពីរ យំស្រែកឮសម្លេង ដូចជាសម្លេងស្រុតផែនដី អស់ពេលវេលា ៤ ខែ ។

ព្រះអានន្ទត្ថេរ អធិដ្ឋានចែកព្រះធាតុរបស់លោកឱ្យដល់ព្រះញាតិទាំងពីរនគរ គឺទាំងសក្យវង្សនគរកបិលពស្តុ និង ទាំងកោលិយវង្សនគរទេវទហៈ ។


ស្ទឹងរោហិណីនារដូវប្រាំង


រូបបដិមាព្រះអង្គប្រសូត

# ព្រះចេតិយរាមគ្រាម នគរទេវទហៈ


កន្លែងតម្កល់ព្រះធាតុពីរនាឡិ


ប្រទក្សិណព្រះចេតិយ



សម័យពុទ្ធកាលនគរនេះហៅថា ទេវទហរាមគ្រាម ខាងស្តេចកោលិយវង្សគ្រប់គ្រងដោយព្រះបាទ សុប្បពុទ្ធ ជាបិតាក្មេករបស់ព្រះអង្គ ហើយជានគរកំណើតរបស់ព្រះនាង សិរិមហាមាយាទេវីពុទ្ធមាតា នគរកំណើតរបស់ព្រះនាងបជាបតិគោតមី ព្រះនាងពិម្ពារាហុលមាតា និង ភិក្ខុទេវទត្ត ។ ព្រះបាទសុប្បពុទ្ធប្រមាថមើលងាយព្រះអង្គត្រូវព្រះធរណីស្រូបក្នុងនគរនេះ ( សេចក្តីពិស្តារមានសម្តែងក្នុងគម្ពីរធម្មបទ បាបវគ្គ ) ។

បច្ចុប្បន្ន នៅក្នុងប្រទេស នេប៉ាល់ មានចម្ងាយពីព្រំប្រទល់ឥណ្ឌាប្រហែល ៤០ គីឡូម៉ែត្រ សព្វថ្ងៃមិនមានជានគរធំដូចមុនទេ អ្វីដែលគួរឱ្យចាប់អារម្មណ៍ជ្រះថ្លា គឺមានសល់ខឿនព្រះចេតិយចាស់មួយដែលធ្លាប់បានតម្កល់ព្រះបរមសារីរិកធាតុពីរនាឡិ បច្ចុប្បន្នព្រះធាតុនោះនៅសុវណ្ណមាលិកចេតិយប្រទេសស្រីលង្កា ។




អង្គុយស្តាប់ពីប្រវត្តិនគរ ទេវទហៈ

# ព្រះចេតិយនៅនគរកបិលពស្តុថ្មី



រូបភាពទាំងអស់នេះគឺជារូបថតនៅនគរកបិលពស្តុថ្មី ការមានកបិលពស្តុថ្មី និងចាស់ ព្រោះមានកើតអន្តរាយសម័យពុទ្ធកាលដោយការបៀតបៀនរបស់ **វិឌូឌភៈ** ទៅលើពួក



ព្រះសង្ឃជនជាតិឥណ្ឌា



ប្រទក្សិណព្រះចេតិយ





សក្យវង្ស ។ សេចក្ដីនេះ ( មានពិស្ដារនៅក្នុងគម្ពីរធម្មបទ បុប្ផវគ្គ ) ទីនេះសព្វថ្ងៃនៅក្នុងប្រទេសឥណ្ឌា យើងបានឃើញខឿនព្រះចេតិយចាស់មួយដែលធ្លាប់បានតម្កល់ព្រះសារីរិកធាតុ ២ នាឡិ នៅទីនេះគួរឱ្យគោរពបូជា "គិតទៅសង្ខារធម៌ទាំងឡាយមិនទៀង" ។

# ភ្នំបាឡាផ្លាវើ ឬ បារបា


ជាតស្រះនៅលើភ្នំ ដែលព្រះពោធិសត្វធ្លាប់បានស្រង់ទឹក

ផ្លូវភ្នំបាឡាផ្លា-
វើ មានចម្ងាយ
៤០ គីឡូម៉ែត្រ
ពីស្រុកពុទ្ធគយា


គុហាព្រះអង្គធ្លាប់គង់នៅ





ព្រះពោធិសត្វ បានមករៀនចម្រើនឈាន ក្នុងសម្នាក់អាឡារតាបស កាឡាមគោត្ត មុនត្រាស់ដឹងជាព្រះពុទ្ធ។ ទីនេះមានគុហាភ្នំ និង ជាតស្រះទឹកព្រះអង្គធ្លាប់ស្រង់គួរឱ្យទស្សនា។ ព្រះអង្គរៀនឈានសមាបត្តិ ក្នុងសម្នាក់តាបសបានស្ទាត់ជំនាញ ហើយយល់ឃើញថា មិនមែនជាធម៌អាចបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណទេ ទើបចូលទៅរៀនក្នុងសម្នាក់ឧទកតាបស រាមបុត្ត។ កាលព្រះអង្គបានសម្រេចសមាបត្តិ ៨ហើយ ព្រះអង្គបានលាតាបសនោះទៅបំពេញទុក្ករកិរិយាអស់ ៦ព្រះវស្សា ទើបបានត្រាស់ដឹង ។


ខាងក្នុងគុហា








ពុទ្ធបដិមាថ្លើមថ្មសម័យចៅព្រះបាទធម្មាសោក
ភ្នំកុក្កុឌុល

# ភ្នំទុក្ខសិរិ

## ( ក្នុងស្រុកពុទ្ធគយា ព្រះអង្គបំពេញទុក្ករកិរិយា )

ព្រះបរមពោធិសត្វ បានចេញពីសម្នាក់ អាឡារតាបស និង ឧទកតាបស មកបំពេញនូវទុក្ករកិរិយា អស់៦ព្រះវស្សា តាមជួរភ្នំរាជគ្រឹះ រហូតមកដល់ទីនេះ ការមិនសោយចង្ហាន់បរិបូរណ៍ ធ្វើឱ្យព្រះអង្គមានព្រះវរកាយ ស្គាំងស្គម ស្លេកស្លាំង បាត់បង់នូវព្រះរូបឆោមមានសម្បុរ







ធ្វើដំណើរឡើងភ្នំ

សៅហ្មង កម្លាំងចុះខ្សោយ មានពេលខ្លះព្រះអង្គសន្លប់បាត់ស្មារតី ព្រះមាតាមហាមាយាទេវបុត្រ មកជួបព្រះអង្គទ្រង់កន្សែងសោកាស្រណោះព្រះរាជបុត្រយ៉ាងក្រៃលែង ។ សក្កទេវរាជ បានចុះមកដេញពិណជាប្រស្នា ព្រះអង្គបានយល់ឃើញ ការបដិបត្តិជាមជ្ឈិមាបដិបទា ទើបឆាន់ចង្ហាន់ល្មមប្រមាណ ពួកបញ្ចវគ្គិយឥសីបាន "ត"





# ព្រះបដិមា ទុក្ករកិរិយា ក្នុងគុហាភ្នំ

















រត់ចោលព្រះអង្គដោយគិតថា ព្រះសិទ្ធត្ថ មិនអាចត្រាស់ដឹងជាព្រះពុទ្ធទេ រហូតមកដល់ថ្ងៃ ១៤ កើត ខែវិសាខ ឆ្នាំរកា ក្នុងបច្ឆិមយាមនៃរាត្រីទ្រង់ព្រះសុបិននិមិត្ត ៥យ៉ាង( អង្គុត្តរនិកាយ បញ្ចកនិបាត) ទើបដឹងថា ព្រះអង្គនឹងត្រាស់ដឹងជាព្រះពុទ្ធយ៉ាងពិតប្រាកដ ។ សព្វថ្ងៃ មានពុទ្ធបរិស័ទជាច្រើនមកនមស្ការបូជាទីនេះ ដោយសេចក្តីសង្វេគក្រៃលែង ភ្នំនេះនៅទិសព្យសាននៃមណ្ឌលពោធិព្រឹក្សប្រហែលជាង ៤ គ.ម. ។



(ភាសាឥណ្ឌាហៅថាភ្នំ ដុង្គេស្វារី យើងតែងហៅថាភ្នំ ទុក្ខសិរិ)












កន្លែងឧបាសិកា សុជាតាថ្វាយមធុបាយាស

ឧបាសិកាសុជាតា នៅឧរុវេលាសេនានិគម បានដល់នូវព្រះរតនត្រៃជាទីពឹង មុនឧបាសិកាទាំងឡាយ ។ កាលនៅក្មេងបានធ្វើសេចក្តីប្រាថ្នា ចំពោះទេវតានៅអាស្រ័យដើមជ្រៃថា បើខ្ញុំបានស្វាមីមានជាតិស្មើគ្នា បានកូនប្រុសមុនគេ ខ្ញុំនឹងធ្វើពលិកម្មថ្វាយមធុបាយាស ដល់លោក ។ សេចក្តីប្រាថ្នាទាំងពីរបានសម្រេចហើយ នាងចង់ធ្វើពលិកម្ម ទើបចាត់ចែងធ្វើមធុបាយាស យ៉ាងឆ្ងាញ់ដោយខ្លួនឯង ។ ក្នុងពេលនាងកំពុងចម្អិនមធុបា-យាសៗ ឡើងវិលជាទក្ខិណាវដ្ត ទឹក និង ផ្សែងនោះក៏មិនបែកហុយចេញក្រៅដែរ ស្តេចមហារាជទាំង-៤ រក្សាចង្ក្រាន មហាព្រហ្មបាំងឆត្រ សក្កទេវរាជ



រូបសំណាកសុជាតាថ្វាយមធុបាយាស



ផ្ទះឧបាសិកាសុជាតា

រុញអុសទេវតាប្រមូលឱជារសក្នុងទ្វីបទាំង ៤ មកដាក់ក្នុងមធុបាយាស ទើបហៅ បុណ្ណាទាសីថា នាងបុណ្ណាថ្ងៃនេះទេវតាជ្រះថ្លាណាស់ នាងប្រញាប់រៀបចំបរិវេណដើមជ្រៃដើម្បីធ្វើពលិកម្ម ។ កាលនោះ លោកយាយ-សុជាតា បានថ្វាយមធុបាយាស និង ថាសមាសចំពោះព្រះពោធិសត្វ ក្នុងថ្ងៃត្រាស់ដឹង ។ កន្លែងថ្វាយចង្ហាន់នៅក្រោមដើមជ្រៃខាងកើតផ្ទះ ឧបាសិកាសុជាតា ប្រ-ហែលជិត ១គ.ម. ។







# ស្ទឹងនេរញ្ជរា


ស្ទឹងនេរញ្ជរា នារដូវប្រាំង
កន្លែងព្រះអង្គផ្សងភាជន៍

បន្ទាប់អំពីព្រះបរមពោធិសត្វ បានសោយនូវមធុបាយាស ៤៩ពំនូតហើយ ទើបព្រះអង្គយកថាសមាសមកកំពង់ទឹកនៅទីនេះ ។ ដោយព្រះអង្គអធិដ្ឋានថា បើបានត្រាស់ដឹង សូមឱ្យថាសអណ្តែតបញ្ច្រាសទឹក ពេលនោះថាសមាសក៏អណ្តែតច្រាសទឹក ៨០ហត្ថ រួចលិចចុះទៅក្នុងបាតដី ទៅទ្រថាសរបស់ព្រះពុទ្ធអង្គមុន ។


ស្ទឹងនេរញ្ជរា នារដូវវស្សា ខ្សែស្ទឹងនេះនៅជិតពោធិមណ្ឌល


រូបគំនូរព្រះអង្គផ្សងភាជន៍



រូបបដិមាសោត្ថិយព្រាហ្មណ៍ថ្វាយស្បូវ ៨ក្តាប់ដល់ព្រះអង្គ
ទីនេះនៅជាប់មាត់ស្ទឹងនេរញ្ជរាខាងកើត

ស្តេចកាឡនាគ ភ្ញាក់ឡើងដោយឮសំឡេងថាសមាសនោះ ក៏ដឹងថា មានព្រះពុទ្ធមួយព្រះអង្គទៀតនឹងបានត្រាស់ដឹង ។




ស្ពានឆ្លងស្ទឹងនេរញ្ជរា



# ព្រះមហាពោធិចេតិយពុទ្ធគយា



ព្រះពុទ្ធបដិមាក្នុងមហាពោធិចេតិយ

ពុទ្ធគយាជាកន្លែងព្រះពុទ្ធគ្រប់ព្រះអង្គត្រាស់ដឹង ព្រោះទីនេះជាផ្ចិតផែនដី ។ សម័យពុទ្ធកាលកន្លែងនេះ ក្នុងឧរុវេលាសេនានិគម នៃដែនមគធៈ បច្ចុប្បន្ននៅក្នុងស្រុកពុទ្ធគយា រដ្ឋ ប៊ិហារប្រទេសឥណ្ឌា មានចម្ងាយ ៥គ.ម.ពីអាកាសយានដ្ឋានគយា, ១៤គ.ម.ពីក្រុងគយា, ៩៦គ.ម.ពីរាជគ្រឹះ, ២៥០គ.ម. ពីពារាណសី ទីនេះនៅខាងលិចស្ទឹងនេរញ្ជរា ប្រហែលជាមិនដល់ ៥០០ ម៉ែត្រ ។ បន្ទាប់ពីព្រះអង្គបានទទួលចង្ហាន់នៃនាង សុជាតា ហើយ ព្រះអង្គបានផ្សងភាជន៍នៅនាស្ទឹងនេរញ្ជរា ព្រះអង្គយាងមកកាន់ពោធិមណ្ឌល ក្នុងវេលាថ្ងៃល្ងាចពួក នាគ គ្រុឌ ទេវតា ព្រហ្ម បូជាព្រះអង្គយ៉ាងក្រៃលែង ។











## ទ្រង់ផ្ចាញ់មារថ្ងៃបានត្រាស់



ព្រះបរមពោធិសត្វទ្រង់បានគង់ក្រោមម្លប់មហា-ពោធិព្រឹក្ស។ មហាពោធិព្រឹក្សមានកម្ពស់ ៥០ ហត្ថ រតនបល្ល័ង្ក ក៏ផុះឡើងកម្ពស់ ១៤ហត្ថ ដោយអំណាចបារមីនៃមហាបុរស ព្រះអង្គក៏បានគង់លើរតនបល្ល័ង្ក ហើយអធិដ្ឋានថា ស្បែក, សរសៃ, ឆ្អឹង, ឈាម របស់អញចូររីងស្ងួតទៅចុះ បើអញមិនបានត្រាស់ដឹងទេ អញមិនក្រោកចេញពីនេះឡើយ ។ លុះដល់ព្រះអាទិត្យជិតអស្តង្គតទៅ ស្រាប់តែ ទេវបុត្តមារ ព្រមទាំងពួកពលសេនា ខាងមុខ១២យោជន៍ ខាងឆ្វេង១២យោជន៍ ខាងស្តាំ១២យោជន៍ ខាងក្រោយ ដល់កណ្តាប់ចក្រវាល ខាងលើ ៩យោជន៍ សម្លេងកក្រើកញាប់ញ័រមកផ្ចាញ់ ដើម្បីនឹងដណ្តើមយករតនបល្ល័ង្កអំពីព្រះអង្គ ទេវបុត្តមារជិះលើដំរីគិរីមេខល មានកម្ពស់ ១៥០យោជន៍និម្មិតដៃ ១ពាន់ កាន់អាវុធផ្សេងៗ សម្តែងឫទ្ធិ ឯពួកពលក៏និម្មិតខ្លួនផ្សេងៗដែរ ទេវបុត្តមារបានបណ្តាលភ្លៀង ៩បែបគឺ ខ្យល់ព្យុះធំ១, ភ្លៀងធំ១, ភ្លៀង-ដុំថ្ម១, ភ្លៀងគ្រឿងប្រហារ១, ភ្លៀងរងើកភ្លើង១, ភ្លៀងផេះក្តៅ១, ភ្លៀងដីខ្សាច់១, ភ្លៀងភក់១, ងងឹតអ័ព្ទ១, ប៉ុន្តែហេតុទាំង ៩ យ៉ាងនេះក៏ក្លាយទៅជាគ្រឿងសក្ការៈបូជាព្រះអង្គវិញ ។ ព្រះអង្គឈ្នះក្រុងមារ ព្រមទាំងរេហ៍ពល ក្នុងពេលនោះដោយបារមី៣០ គឺ បារមី ១០, ឧបបារមី១០, បរមត្ថបារមី១០, មហាបរិច្ចាគ ៥ និង ចរិយា ៣ រីឯមារ កាលបើចាញ់តេជះ ព្រះមហាបុរសដូច្នេះហើយ ក៏លើកហត្ថាទាំង ១ពាន់ ដាក់លើសិរសានមស្ការថា "នមោ តេ បុរិសាជញ្ញ" ដូច្នេះជាដើមក៏ហោះបាត់អំពីទីនោះហោង។ បន្ទាប់ពីពួកមារបានរត់ទៅ ព្រះអង្គទ្រង់គង់លើរតនបល្ល័ង្ក ពិចារណាធម៌ក្នុងបឋមយាមនៃរាត្រី ព្រះអង្គបានសម្រេចបុព្វេនិវាសានុស្សតិញ្ញាណ, ពាក់កណ្តាលរាត្រីព្រះអង្គសម្រេច ទិព្វចក្ខុញ្ញាណ, ជិតភ្លឺទ្រង់ពិចារណាបដិច្ចសមុប្បាទ១២ បានត្រាស់ដឹងជាព្រះពុទ្ធ ផែនដីក៏កម្រើកញាប់ញ័រចំនួន ១២ដង ផងដែរ។

"ត្រាស់ដឹងក្នុងថ្ងៃពុធ ១៥កើត ខែពិសាខ ឆ្នាំរកា"

*សូមពុទ្ធបរិស័ទជ្រាបសេចក្តីនេះដោយពិស្តារក្នុងសៀវភៅពុទ្ធប្បវត្តិទាំងឡាយផងចុះ ។*




## កាលព្រះអង្គបានត្រាស់ដឹងហើយទ្រង់បន្លឺឧទានដូចព្រះពុទ្ធរាល់ព្រះអង្គថា:









***អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ***
***គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ***
***គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ***
***សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ***
***វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយ មជ្ឈគា ។***

ប្រែថា: យើងស្វែងរកមេជាងធ្វើផ្ទះគឺតណ្ហា កាលមិនបានជួបបានត្រាច់រង្គត់ទៅរហូត ជាតិសង្សារមិនមែនតិច ការកើតរឿយៗជាទុក្ខ ម្នាលមេជាងអ្នកធ្វើផ្ទះ គឺតណ្ហា យើងជួបអ្នកហើយ អ្នកសាងផ្ទះដល់យើងទៀតមិនបានឡើយ បង្កង់ផ្ទះរបស់អ្នក យើងកាច់អស់ហើយ ដំបូលគឺអវិជ្ជាយើងបានកម្ចាត់ចេញហើយ ចិត្តរបស់យើង ដល់នូវវិសង្ខារ គឺព្រះនិព្វាន ដែលបច្ច័យតាក់តែងទៀតមិនបាន ព្រោះយើងទម្លុះធម៌ដែលជាទីអស់ទៅនៃតណ្ហាហើយ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ដឹងដំបូង ប្រថាប់នៅលើរតនបល្ល័ង្ក នាមណ្ឌលពោធិព្រឹក្ស ជិតស្ទឹងនេរញ្ជរា ក្នុងឧរុវេលាសេនានិគម សោយវិមុត្តិសុខអស់៧ថ្ងៃ ។



























# ពុទ្ធគយាជាទីជ្រះថ្លា

កាលព្រះអង្គបានត្រាស់ដឹងហើយ ពួកនាគ គ្រុឌ ទេវតា និង ពួកព្រហ្មទាំងឡាយបាន ថ្វាយផ្កាគ្រឿងក្រអូប និង ថ្វាយសព្ទសាធុ-ការពរចំពោះព្រះអង្គយ៉ាងក្រៃលែង។ បច្ចុ-ប្បន្ន ទីនេះជាពុទ្ធស្ថានដ៏ឧត្តម ដោយមាន មហាពោធិព្រឹក្ស និង មហាពោធិចេតិយ កម្ពស់ ៥៥ម៉ែត្រ ដែលបានដាក់បញ្ចូលជា បេតិកភណ្ឌពិភពលោក ដោយអង្គការ **យូនិស្កូ** មានពុទ្ធសាសនិកជន មកពីបណ្តា ប្រទេសលើពិភពលោកគោរពបូជា ទាំង យប់ទាំងថ្ងៃ ច្រើនជាងកន្លែងដទៃ។

ពុទ្ធបរិស័ទខ្មែរ ១៩៧នាក់ ដង្ហែគ្រឿងសក្ការៈបូជាព្រះមហា-ពោធិព្រឹក្ស ដែលដឹកនាំដោយលោកគ្រូធម្មាចារ្យ តែច ទិមុត្ត

# ប្រវត្តិសង្ខេបនៃមហាពោធិព្រឹក្សទាំង ៤អង្គ



ត្រង់ផ្ចិតផែនដីជាកន្លែងពន្លកឡើងនៃ មហាពោធិព្រឹក្សរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។ ព្រះបរិនាយកនៃយើង បានត្រាស់ដឹងក្រោមដើមអស្សត្ថព្រឹក្ស ( ពោធិ៍បាយ ) ដើមពោធិព្រឹក្សបានពន្លកឡើងក្នុងថ្ងៃសុក្រ ១៥កើត ខែពិសាខ ឆ្នាំច ក្នុងពេលដំណាលនឹងព្រះអង្គប្រសូត ។ មហាពោធិព្រឹក្សទី១ បានស្លាប់នៅក្នុង ព.ស.២៧២ វស្សា ក្នុងអាយុ ៣៥២ឆ្នាំ ស្លាប់ដោយសេចក្តីច្រណែនរបស់នាង មហីសុន្ទរី មហេសីទីបួននៃព្រះបាទធម្មាសោក ។ មហាពោធិព្រឹក្សដើមទី២ ព្រះបាទធម្មាសោកបាន









ប្រតិស្ឋានមានអាយុ៨៩១ឆ្នាំ ស្លាប់ក្នុង ព.ស.១១៦៣វស្សា ដោយការបៀតបៀននៃស្តេចសាសង្កា ។ មហាពោធិព្រឹក្សដើមទី៣ បានប្រតិស្ឋានឡើងដោយស្តេចឈ្មោះ បុរណៈវរមា មានអាយុ ១២៥៨ ឆ្នាំ ស្លាប់ក្នុង ព.ស.២៤២១វស្សា ដោយចាស់ជរាទ្រុឌទ្រោម ។ មហាពោធិ៍អស្សត្ថទី៤ ដាំដោយឧត្តមសេនីយ៍ជនជាតិអង់គ្លេសឈ្មោះ ហ្សឺនីងខានហោម មហាពោធិព្រឹក្សបច្ចុប្បន្នមានអាយុ ១៣៣ឆ្នាំ គិតមកដល់ ព.ស.២៥៥៤វស្សានេះ ។





# ភ្នំគយាសីសៈ តំបន់កន្លែងសម្តែងអាទិត្តបរិយាយសូត្រ

នៅមិនឆ្ងាយពីទីរួមស្រុកគយាប៉ុន្មាន យើងឃើញមានភ្នំមួយឈ្មោះថា ភ្នំគយាសីសៈ បច្ចុប្បន្នបរិស្ថានទីនេះពុំសូវល្អប៉ុន្មានទេ គួរឱ្យស្រណោះសង្វេគក្រៃពេក។ ក្នុងវិន័យបិដកលេខ៦ ទំព័រ៧៦ សម្តែងថា កាលពួកជដិលទាំងមួយពាន់រូប នៅក្បែរស្ទឹងគយា-សីសៈបានបួសជាភិក្ខុហើយ មកស្តាប់អាទិត្តបរិយា-យសូត្រ(ចក្ខុជារបស់ក្តៅ ជាដើម) នៅតំបន់គយា-សីសៈ ហើយបានសម្រេចជាព្រះអរហន្តទាំងអស់។






ភ្នំគយាសីសៈ

# វត្ត៥៨នៅជុំវិញជិតមណ្ឌលពោធិព្រឹក្ស

បច្ចុប្បន្ន មានវត្តព្រះពុទ្ធសាសនាដែលព្រះសង្ឃ និងពុទ្ធបរិស័ទក្នុងបណ្តាប្រទេសនានា មកកសាងវត្តជិតមណ្ឌលពោធិព្រឹក្ស ដើម្បីស្នាក់នៅធ្វើបុណ្យកុសល ក្នុងនោះមាន៥៨វត្ត បើរាប់ទាំងវត្តតូចផងគឺ១០៣វត្ត ដូចជា វត្តខ្មែរ វត្តវៀតណាម វត្តថៃ វត្តស្រីលង្កា វត្តភូមា វត្តចិន វត្តជប៉ុន វត្តកូរ៉េ វត្តនេប៉ាល់ វត្តឡាវជាដើម។


វត្តខ្មែរពុទ្ធគយា




វត្តផ្សេងៗនៅពុទ្ធគយា



# សត្តមហាឋាន

## ៧កន្លែងព្រះអង្គប្រថាប់គង់ក្រោយត្រាស់ដឹង




### ១-ពោធិបល្ល័ង្ក

ក្នុងសប្តាហ៍ទី១ ព្រះអង្គគង់ប្រថាប់លើពោធិបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្ស ហើយចូលសមាបត្តិសោយនូវវិមុត្តិសុខ។




### ២-អនិមិសកចេតិយ

ក្នុងសប្តាហ៍ទី២ អនិមិសកចេតិយ កន្លែងព្រះអង្គទ្រង់ឈរទតមើលមហាពោធិបល្ល័ង្ក ដោយមិនពព្រិចព្រះនេត្រអស់៧ថ្ងៃ ចេតិយនេះ នៅទិសឦសាននៃមហាពោធិចេតិយ ។




### ៣-រតនចង្ក្រម

ក្នុងសប្តាហ៍ទី៣ ព្រះបរមសាស្តា ទ្រង់និម្មិតទីចង្ក្រមនៅចន្លោះ ពោធិបល្ល័ង្ក និង អនិមិសកចេតិយ ទ្រង់យាងចង្ក្រម លើទីចង្ក្រម អស់ ៧ថ្ងៃ ។

## ៤-រតនឃរចេតិយ

ក្នុងសប្តាហ៍ទី៤ ពួកទេវតា និម្មិតផ្ទះកែវនៅទិសពាយព្យនៃមហាពោធិព្រឹក្ស ព្រះអង្គប្រថាប់គង់ពិចារណាព្រះអភិធម្ម ៧គម្ពីរ ក្នុងផ្ទះកែវនេះអស់ ៧ថ្ងៃ (សព្វថ្ងៃទីនេះមានព្រះចេតិយជាតំណាង) ។


រតនឃរចេតិយ

## ៥-ដើមអជបាលនិគ្រោធ

ក្នុងសប្តាហ៍ទី៥ ព្រះអង្គប្រថាប់គង់ក្រោមដើមអជបាលនិគ្រោធ (គឺកន្លែងឧបាសិកាសុជាតា បានថ្វាយចង្ហាន់នៅខាងកើតស្ទឹងនេរញ្ជរា) ព្រះអង្គ សោយនូវវិមុត្តិសុខអស់ ៧ថ្ងៃ ។


ដើមអជបាលនិគ្រោធ

## ៦-ស្រះមុច្ចលិន្ទ

ក្នុងសប្តាហ៍ទី៦ ព្រះអង្គគង់ប្រថាប់ក្នុងរង្វេលមុច្ចលិន្ទនាគរាជ ក្បែរស្រះមុច្ចលិន្ទ ព្រះអង្គសោយវិមុត្តិសុខអស់ ៧ថ្ងៃ ។ (សព្វថ្ងៃមានភូមិអ្នកស្រុកនៅជិតខាង)


ស្រះមុច្ចលិន្ទ

## ៧-ដើមរាជាយតនៈ

ក្នុងសប្តាហ៍ទី៧ ព្រះអង្គប្រថាប់គង់ក្រោមដើម រាជាយតនៈ សោយវិមុត្តិសុខអស់ ៧ថ្ងៃ ។


ដើមរាជាយតនៈ

# សត្តមហាឋាន

**ក្នុងសប្តាហ៍ទី១** គឺចាប់ពីថ្ងៃព្រហស្បតិ៍ ១រោច ខែពិសាខដល់ថ្ងៃព្រហស្បតិ៍ ៨ រោច ទ្រង់គង់នៅលើរតនបល្ល័ង្កក្រោមដើមពោធិព្រឹក្ស ជាទីដែលទ្រង់បានត្រាស់នោះឯង ដើម្បីពិចារណាធម៌ ដែលទ្រង់បានត្រាស់ដឹងហើយ ។

**ក្នុងសប្តាហ៍ទី២** ចាប់ពីថ្ងៃព្រហស្បតិ៍ ៨រោច ទ្រង់ធ្វើយមកបាដិហារ្យ ដោះសេចក្តីសង្ស័យរបស់ទេវតា ហើយទ្រង់ចុះទៅគង់នៅខាងទិសឦសាននៃរតនបល្ល័ង្ក រួចទតរតនបល្ល័ង្ក ដោយមិនពព្រិចព្រះនេត្រសោះអស់ ៧ថ្ងៃ រហូតដល់ថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ទីនោះហៅថា អនិមិសកចេតិយ ។

**ក្នុងសប្តាហ៍ទី៣** ចាប់ពីព្រឹកថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខទៅដល់ព្រឹកថ្ងៃព្រហស្បតិ៍ ៧កើត ខែជេស្ឋ ទ្រង់យាងចង្រ្កមរវាងអនិមិសចេតិយ និងមណ្ឌលពោធិព្រឹក្សអស់ ៧ថ្ងៃ ហៅថា រតនចង្រ្កម ។

**ក្នុងសប្តាហ៍ទី៤** ចាប់ពីព្រឹកនៃថ្ងៃព្រហស្បតិ៍ ៧កើត ខែជេស្ឋ ទ្រង់គង់នៅក្នុងផ្ទះកែវដែលទេវតានិម្មិតថ្វាយ នាខាងទិសពាយព្យនៃគល់ពោធិព្រឹក្សអស់៧ថ្ងៃ ព្រះអង្គពិចារណាព្រះអភិធម្ម ៧គម្ពីរ គឺ *ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលបញ្ញត្តិ កថាវត្ថុ យមកៈ* ព្រះរស្មីមិនទាន់ផ្សាយចេញពីសរីរៈទេ រហូតពិចារណាគម្ពីរមហាបដ្ឋាន អនន្តនយ ទីបំផុតមានព្រះរស្មីផ្សាយចេញពីព្រះវរកាយព្រះអង្គ ។

**ក្នុងសប្តាហ៍ទី៥** ចាប់ពីថ្ងៃព្រហស្បតិ៍ ១៤កើត ខែជេស្ឋ ទ្រង់យាងទៅគង់នៅក្រោមដើមអជបាលនិគ្រោធ ដើមជ្រៃដែលពួកអ្នកគង្វាល ចៀម ពពែ តែងជ្រកអាស្រ័យនៅអស់ ៧ថ្ងៃ ដើម្បីពិចារណាព្រះសទ្ធម្ម សោយវិមុត្តិសុខ ព្រះអង្គបានជួបព្រាហ្មណ៍ឈ្មោះថា ទិដ្ឋមង្គលិកៈ ។ តមកធីតានៃមារគឺ នាង តណ្ហា អរតីរាគា បានមកលួងលោមព្រះអង្គដោយអាការៈផ្សេងៗ តែមិនសម្រេចក៏ត្រឡប់ទៅឋានរបស់ខ្លួនវិញ ។

<u>បញ្ជាក់:</u> ពេលក្រោយមកបន្ទាប់អំពី ៧ សប្តាហ៍ ព្រះអង្គបានមកគង់ក្រោមដើមអជបាលនិគ្រោធវិញ សហម្បតិព្រហ្ម ចុះមកអារាធនា សូមឱ្យព្រះអង្គសម្តែងធម៌ ។

**ក្នុងសប្តាហ៍ទី៦** ចាប់ពីថ្ងៃព្រហស្បតិ៍ ៦រោច ខែជេស្ឋ ទ្រង់យាងទៅគង់នៅក្បែរស្រះមុច្ចលិន្ទ ។ នៅទីនោះបាននាគរាជឈ្មោះថា មុច្ចលិន្ទ ចេញមកនិម្មិតកាយដ៏ធំ ដើម្បីបាំងភ្លៀងខ្យល់ ដែលបង្អុរនិងបក់មក ព្រះអង្គបានបន្លឺឧទាន ២គាថា *សុខោ វិវេកោ តុដ្ឋស្ស* ...ជាដើម ទ្រង់គង់អស់ ៧ថ្ងៃ ។ ស្រះមុច្ចលិន្ទនៅខាងត្បូងពោធិមណ្ឌល ប្រហែល ៣ គ.ម. ។

**ក្នុងសប្តាហ៍ទី៧** ចាប់ពីថ្ងៃព្រហស្បតិ៍ ១៣រោច ខែជេស្ឋ ដល់ថ្ងៃ៥កើត ខែអាសាឍ ទ្រង់យាងទៅគង់នៅក្រោមដើមកែស ១ដើមអស់ ៧ថ្ងៃ។ ៤៩ ថ្ងៃកន្លងទៅ រាប់តាំងពីពេលបានត្រាស់មក ទ្រង់ពុំបានសោយចង្ហាន់ទេ គឺសោយតែវិមុត្តិសុខ។ លុះដល់ចុងសប្តាហ៍ទី៧ ទើបព្រះឥន្ទយកទឹកខ្ចុរព្រះឱស ហើយយកផ្លែសម៉ទិព្វ មកថ្វាយព្រះអង្គៗ ទ្រង់ទទួលមកសោយ។ បន្ទាប់មកទៀតមានពាណិជ ពីរនាក់បងប្អូនឈ្មោះតបុស្សៈ និងភល្លិកៈ មកពីឧក្កលាជនបទមកថ្វាយបង្គំ និងប្រគេនសត្តុវចំពោះព្រះអង្គហើយពេលនោះមហារាជទាំង ៤អង្គ យកបាត្រថ្វាយព្រះអង្គ ហើយពាណិជនោះសូមដល់នូវព្រះពុទ្ធ ព្រះធម៌ជាទីពឹងទីរលឹក និងសូមនូវវត្ថុជាទីនឹករលឹកពីព្រះអង្គៗ ក៏យកព្រះហស្តអង្អែលព្រះសីសៈ បានព្រះកេសា៨សរសៃ ប្រទានដល់ពាណិជៗ បានយកមកបញ្ចុះនៅ សិង្គុត្តរចេតិយប្រទេសភូមា ។ ទីនោះនៅខាងត្បូងនៃមហាពោធិ៍ ប្រហែលជាង ៣គ.ម.។

# ព្រះពុទ្ធរូបព្រះអង្គធំនៅពុទ្ធគយា















ព្រះពុទ្ធរូបមួយអង្គនេះ បានចាប់ផ្ដើមកសាងពីឆ្នាំ ១៩៨២ កសាងដោយរាជរដ្ឋាភិបាល **ជប៉ុន** នៅមិនឆ្ងាយពីមណ្ឌលពោធិព្រឹក្សប្រមាណជា១000 ម៉ែត្រ។ ហើយក៏នៅក្បែរវត្តខ្មែរពុទ្ធគយាផងដែរ ពុទ្ធរូបនេះមានកម្ពស់ ២៤ម៉ែត្រ មានរូបព្រះអរហន្តសាវ័ក នៅសងខាងព្រះអង្គគួរឱ្យជ្រះថ្លា។



# វត្តស្រីលង្កានៅជិតពោធិព្រឹក្ស









ដោយបានអនុញ្ញាតពីព្រះសង្ឃ ចៅអធិការ វត្តស្រីលង្កាដែលនៅក្បែរ មហាពោធិព្រឹក្ស ពុទ្ធបរិស័ទយើង បានទូលនូវព្រះសារីរិកធាតុ របស់ព្រះសម្មាសម្ពុទ្ធ និង ទូលនូវព្រះធាតុរបស់ព្រះអគ្គសាវ័កទាំងពីរ ប្រកបដោយសេចក្តីជ្រះថ្លា ដ៏ក្រៃលែង ។ មើលព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធ និង អគ្គសាវ័កទាំងពីរអង្គ ក៏ជ្រះថ្លាបូជា ដោយគ្រឿងសក្ការៈផ្សេងៗ ចំពោះព្រះរមសារីរិកធាតុ។



ទូលព្រះសារីរិកធាតុ





# វត្តខ្មែរពុទ្ធគយា



ព្រះភិក្ខុ ហ៊ត សុផល ព្រះភិក្ខុ ចាន់ សាទិន



ក្នុងវត្តខ្មែរពុទ្ធគយា



វត្តខ្មែរពុទ្ធគយា កំពុងកសាង













វត្តខ្មែរពុទ្ធគយា កសាងដោយព្រះសង្ឃខ្មែរ នៅពុទ្ធគយា មានព្រះភិក្ខុ ញើយ មេត្តា ជាប្រធាន ដែលមានពុទ្ធបរិស័ទក្នុង និង ក្រៅប្រទេសឧបត្ថម្ភ ។ វត្តខ្មែរពុទ្ធគយាជាប្រយោជន៍សម្រាប់ព្រះសង្ឃគង់នៅ ព្រមទាំងសម្រាប់ភ្ញៀវពុទ្ធបរិស័ទ ដែលអញ្ជើញមកកាន់ដែនដីពុទ្ធភូមិនេះ វត្តនេះស្ថិតនៅជិតពុទ្ធរូបព្រះអង្គធំ ក្បែរមណ្ឌលពោធិព្រឹក្សប្រហែល ១០០០ម៉ែត្រ។

# ស្ទឹងគយាសីសៈ ជិតកន្លែងសម្តែងបាដិហារ្យប្រោសពួកជដិល



ព្រះអង្គសម្តែងបាដិហារ្យប្រោសជដិល ដែលមានមានៈ ថាខ្លួនជាព្រះអរហន្ត ។ បន្ទាប់ពីព្រះអង្គសម្តែងឫទ្ធិហើយ ឧរុវេលកស្សប និង កូនសិស្សព្រមទាំង នទីកស្សប គយាកស្សប ជាប្អូន និងបរិវារទាំងអស់បានបួស រួចស្តាប់នូវ អាទិត្តបរិយាយសូត្រ ពេលនោះបានសម្រេចជា ព្រះអរហន្តទាំងអស់គ្នា ។ សម័យនោះ ទីនេះមានរោងភ្លើងនាគរាជអាស្រ័យនៅ ព្រះអង្គបានផ្ចាញ់ហើយ ។

បច្ចុប្បន្នទីនេះ សាសនាហិណ្ឌូកាន់កាប់រក្សា ។ ស្ទឹងគយាសីសៈ នារដូវប្រាំងមិនមានទឹកទេ មានតែខ្សាច់នៅពេញបាតស្ទឹង ។



ក្នុងស្ទឹងគយាសីសៈ

កន្លែងសម្តែងបាដិហារ្យប្រោសជដិលជិតស្ទឹងគយាសីសៈ

ព្រះពុទ្ធជាម្ចាស់សម្តែង ៣៥០០បាដិហារ្យ ដល់ពួកជដិល មានសេចក្តីពិស្តារយ៉ាងពីរោះក្នុងវិន័យបិដកលេខ៦ ទំព័រ៧៦ ។

# ទន្លេគង្គានៅក្រុងពារាណសី



ដងទន្លេគង្គា

ក្រុងពារាណសីក្នុងដែនកាសីនៃនគរមគធៈគ្រប់-គ្រងដោយព្រះបាទពិម្ពិសារ មានចម្ងាយពីពុទ្ធគយា ១៨យោជន៍ បច្ចុប្បន្នឥណ្ឌាហៅថា វ៉ារ៉ាណាស៊ី ស្ថិតក្នុងរដ្ឋយូពី។ ចម្ងាយផ្លូវឡាន ២៥០ គ.ម. ពីពុទ្ធ-គយា។ ៧៨០ គ.ម. ពីទីក្រុងញូវដែលី។







ពារាណសី ជាទីក្រុងដែលចាស់ជាងគេលើពិភព-លោក   មានប្រវត្តិក្នុងគម្ពីរព្រះជាតកជាច្រើន។



ស្ពានរថភ្លើង និង រថយន្តឆ្លងទន្លេ



ទន្លេគង្គានៅក្បែរក្រុងពារាណសី ជាទន្លេមានឈ្មោះ ល្បីល្បាញហូរមកពីភ្នំហេម-ពាន្ត  ប្រជាជននៅទីនេះ  ភាគច្រើនមានជំនឿយល់ខុសថា ទឹកទន្លេនេះអាចលាងបាបបាន។ ទន្លេគង្គាមានប្រវត្តិក្នុងព្រះពុទ្ធសាសនាជាច្រើន   សព្វថ្ងៃបរិស្ថាននៅទីនេះពុំសូវល្អប៉ុន្មានទេព្រោះសាកសពមនុស្សដែលស្លាប់ហើយ គេបណ្តែតក្នុងទន្លេនេះជាច្រើន។





ជិះទូកក្នុងទន្លេគង្គា

# ព្រះចៅគណ្ឌីស្តូបនៅពារាណសី





បញ្ជាក់ថា: នៅជិតនេះក៏មានវត្តខ្មែរពារាណសីមួយផង ដែរដែលកសាងដោយ ព្រះភិក្ខុ **សែម ប៊ិច** គួរឱ្យជ្រះថ្លា។

កន្លែងព្រះអង្គជួបបញ្ចវគ្គិយ៍ ដំបូង ទីនេះមានព្រះចេតិយធំមួយ គួរឱ្យអស្ចារ្យណាស់ ធ្វើអំពីឥដ្ឋក្នុងចន្លោះពុទ្ធ ស.វ. ទី៤ ដល់ទី៦ ទីនេះនៅខាងជើងភាគខាងកើត នៃទីក្រុងពារាណសី និងមានចម្ងាយ ១៣គ.ម.ពីទីក្រុង។ កាលព្រះអង្គទើបបានត្រាស់ដឹងដំបូង ព្រហ្មបានអារាធនាសូមឱ្យព្រះអង្គសម្តែងធម៌ ទ្រង់បានពិចារណា ដល់អាឡារតាបស និង ឧទកតាបស តែតាបសទាំងនោះបានស្លាប់ទៅហើយ ទើបទ្រង់នឹករលឹកដល់ឥសីទាំង ៥ មានកោណ្ឌញ្ញៈ ជាដើម ដែលធ្លាប់បម្រើព្រះអង្គ ហើយបានស្តេចយាងមក ពីឧរុវេលាសេនានិគម (ពុទ្ធគយា) យាងដោយព្រះបាទអស់ ១៨យោជន៍ មកដល់ព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ក្នុងថ្ងៃ ១៥កើត ខែអាសាឍ ឆ្នាំរកា តែកាលនោះឥសីទាំង ៥ មិនជឿថា ព្រះអង្គបានត្រាស់ជាព្រះពុទ្ធទេ ព្រះអង្គពន្យល់ជាច្រើនដង ទើបឥសីនោះជឿ ហើយព្រះអង្គសម្តែងព្រះធម៌ នៅឯកន្លែងព្រះពុទ្ធគ្រប់ព្រះអង្គបានគង់សម្តែងនោះ នៅជិត ព្រះចៅគណ្ឌីស្តូប (មានពិស្តារក្នុងបិដកលេខ៦ ទំព័រ២៨)។



# ធម្មេក្ខស្តូប

## នៅពារាណសី ឬ សារនាថ









ធម្មេក្ខស្តូប(អចលចេតិយ) នៅក្នុង ឥសិបតនមិគទាយវ័ន ក្បែរក្រុងពា-រាណសី កសាងក្នុងសម័យព្រះបាទ ធម្មាសោក ហើយត្រូវបានជួសជុលបន្ត-បន្ទាប់មក ស្តូបនេះមានកម្ពស់ ៤២.៦ម៉ែត្រ និង វិជ្ជមាត្រក្រោម ៣៣.៥៣ ម៉ែត្រ វិជ្ជមាត្រលើ ២៨.៥ម៉ែត្រ ប្របវែងជុំវិញ ៩០ម៉ែត្រ ។ មុនសម័យពុទ្ធកាលទីនេះឈ្មោះ ឥសិបតនមិគទាយវ័ន មានព្រះ បច្ចេកពុទ្ធ ជាច្រើនអង្គ ធ្លាប់បានគង់នៅទីនេះ ។ ព្រះសក្យមុនីសម្ពុទ្ធ ទ្រង់សម្តែងព្រះធម្មចក្ក ជាបឋមទេសនារបស់ព្រះអង្គ នាឥសិបតនមិគទាយវ័ន ជិតក្រុង ពារាណសី ប្រោសបញ្ចវគ្គិយ៍ភិក្ខុ ព្រះអញ្ញាកោណ្ឌញ្ញៈមួយអង្គ និង ទេវតាព្រហ្ម ១៨ កោដិ បានសម្រេចគុណធម៌ ។



# ព្រះគន្ធកុដិក្នុងឥសិបតនមិគទាយវ័ន


ព្រះគន្ធកុដិថតពីខាងមុខ

រូបភាពទាំងនេះ ជាស្នាមខឿន ព្រះគន្ធកុដិ ដែលព្រះសម្មាសម្ពុទ្ធ ធ្លាប់បានគង់ប្រថាប់ នៅក្នុងវស្សាទី១ កាលនោះព្រះអង្គសម្តែងធម៌ ប្រោសដល់ព្រះយស មាតា បិតា និង សម្លាញ់របស់លោក ។ ព្រះយស និង សម្លាញ់ ៥៤នាក់ បានបួសសម្រេចជាព្រះអរហន្ត កាលនោះ មាន ព្រះអរហន្ត ៦១ អង្គ គង់នៅទីនេះ ។



ពេលចេញវស្សាព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តីបាន រួចពីអន្ទាក់របស់មនុស្ស និង ទេវតាហើយ ដូច្នេះ ចូរធ្វើដំណើរបែកគ្នា ចេញទៅផ្សព្វផ្សាយ ព្រះធម៌ក្នុងស្រុកនានា ដើម្បីជាប្រយោជន៍ដល់មនុស្ស ទេវតា ។ ហើយចូរសម្តែងធម៌ ល្អបទដើម បទកណ្តាល និង បទចុង ប្រកបអត្ថ និងព្យញ្ជនៈដោយល្អចុះ

( មូលគន្ធកុដិនេះនៅជិតធម្មេក្ខស្តូប ប្រមាណ ១០០ម៉ែត្រ ) ។


ធម្មរាជិកស្តូប កន្លែងសម្តែង អនត្ត-លក្ខណៈសូត្រ ជាប់នឹងព្រះគន្ធកុដិ



# វត្តស្រីលង្កានៅជិតធម្មេកស្តូប














លោកគ្រូធម្មាចារ្យ គាំ អ៊ីច
លោកគ្រូធម្មាចារ្យ កែច ចិម្មុត្ត







នៅជិតធម្មេកស្តូប មានវត្តជនជាតិស្រីលង្កាមួយដែលមានឈ្មោះល្បីល្បាញក្នុងក្រុងពារាណសី ដែលកសាងក្នុង ព.ស.២៤៧៤, គ.ស. ១៩៣០ ដោយជនជាតិស្រីលង្កាឈ្មោះ អនាគារិកធម្មបាល ឧបាសក ក្នុងវត្តនេះ មានព្រះគន្ធកុដិ តម្កល់ព្រះបរមសារីរិកធាតុ និង មហាពោធិព្រឹក្ស ។ ព្រះពុទ្ធបដិមាសម្តែងធម្មចក្ក ផ្ទាំងអក្សរធម្មចក្កប្បវត្តនសូត្រ ជាច្រើនភាសា ក្នុងនោះក៏មានផ្ទាំងធម្មចក្ក ជាភាសាខ្មែរឆ្លាក់លើថ្មម៉ាបយ៉ាងខ្មៅរលោង ដែលដឹកនាំកសាងដោយ លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ព្រោះហេតុដូច្នេះ បានជាវត្តនេះមានពុទ្ធបរិស័ទជាច្រើនមកគោរពបូជា ។

# ព្រះគន្ធកុដិថ្មី

ពុទ្ធបរិស័ទយើងទាំងអស់គ្នាបានទស្សនា និង ទូលព្រះបរមសារីរិកធាតុ ហើយធ្វើការបូជា ដោយគ្រឿងសក្ការៈ ជាច្រើន នៅក្នុងព្រះគន្ធកុដិថ្មី ក្នុងវត្តស្រីលង្កាជិតធម្មេកូស្តូប ប្រកបដោយសេចក្តីជ្រះថ្លាជាពន់ពេក ។



រូបព្រះពុទ្ធបដិមាថ្មី



ព្រះពុទ្ធបដិមា សម័យព្រះបាទ អសោក ឥឡូវ នៅក្នុងសារមន្ទីរ ក្រុងពារាណសី



ព្រះគន្ធកុដិតម្កល់ព្រះសារីរិកធាតុ







ទូលព្រះសារីរិកធាតុ

ព្រះសង្ឃស្រីលង្កាជូនរូបព្រះគន្ធកុដិដល់លោកគ្រូធម្មាចារ្យ កែវ ខិមុត្ត





ផ្លូវចូលពីមុខព្រះគន្ធកុដិថ្មី

# ក្រុងរាជគ្រឹះដែនមគធៈ

ពាក្យថា: រាជគ្រឹះ ជារាជវាំងរបស់ព្រះរាជា មានទីតាំងខាងលិចនៃប្រទេសឥណ្ឌា ស្ថិតនៅក្នុងរដ្ឋ បិហារ មានចម្ងាយ ១០២ គ.ម. ពីទីក្រុងបតនៈ ៩៦ គ.ម.ពីពុទ្ធគយា ។ ក្នុងគម្ពីរមហាវង្ស ព្រះបាទ ពិម្ពិសារ បានគ្រងរាជសម្បត្តិ ក្នុងព្រះជន្ម ១៥ ព្រះវស្សា សោយរាជ្យបាន ១៦ឆ្នាំ បានជួបព្រះសម្មាសម្ពុទ្ធ ស្តាប់ព្រះធម៌ទេសនា សម្រេចជាព្រះអរិយបុគ្គល ក្នុងព្រះជន្ម ៣១ព្រះវស្សា ។ នគរនេះសម្បូណ៌ដោយមហាសេដ្ឋី មានជោតិកសេដ្ឋីជាដើម ហើយក៏ជាស្រុកកំណើតរបស់ព្រះអរិយបុគ្គលជាច្រើនអង្គ ក្នុងសម័យនោះ ក្នុងនគរនេះមានមនុស្សចំនួន ១៨០លាននាក់ ។ ព្រះបាទពិម្ពិសារ ទំនុកបម្រុងព្រះពុទ្ធសាសនាបាន ៣៦ឆ្នាំ ព្រះអង្គសោយទិវង្គត ក្នុងព្រះជន្ម ៦៧ព្រះវស្សា មុនព្រះសម្មាសម្ពុទ្ធបរិនិព្វាន ៨ឆ្នាំ ដោយព្រះបាទ អជាតសត្តុ ជារាជបុត្ររបស់ព្រះអង្គជាអ្នកធ្វើគុត ។

តមកទៀតព្រះបាទអជាតសត្តុ គ្រប់គ្រងនគរនេះសោយរាជ្យបាន ៣២ឆ្នាំ ត្រូវឧទយភទ្ទ ជារាជបុត្រធ្វើគុត ដណ្តើមរាជ្យ ។ ព្រះបាទឧទយភទ្ទ សោយរាជ្យបាន១៦ឆ្នាំត្រូវអនុរុទ្ធ ជារាជបុត្រធ្វើគុតដណ្តើមរាជ្យ, ព្រះបាទអនុរុទ្ធ សោយរាជ្យបាន ៤ឆ្នាំ ត្រូវមុណ្ឌៈ ជារាជបុត្រធ្វើគត់ដណ្តើមរាជ្យ ព្រះបាទ មុណ្ឌៈ សោយរាជ្យបាន ៤ឆ្នាំ ត្រូវនាគទាសកៈ ជារាជបុត្រធ្វើគត់ដណ្តើមរាជ្យ ព្រះបាទនាគទាសកៈ សោយរាជ្យបាន ២៤ឆ្នាំក្នុង ព.ស.៧២ ត្រូវផ្លាស់វង្សសោយរាជ្យ (វង្សខាងវេសាលីពីមុន ហូរហែរហូតដល់ ព្រះបាទធម្មាសោកសោយរាជ្យ ព.ស. ២១៨ ប៉ុន្តែមិននៅក្នុងនគររាជគ្រឹះនេះទេគឺ នៅឯបាដលិបុត្រ ឬបតនៈជិតវេសាលី) ។ ក្រុងរាជគ្រឹះមានភ្នំព័ទ្ធព័ទ្ធជុំវិញគឺ ភ្នំវេបុល្លៈ ភ្នំវេភារៈ ភ្នំគិជ្ឈកូដ ភ្នំឥសិគិលិ ភ្នំបណ្ឌវៈ ។ សម័យពុទ្ធកាល មានវត្តជាច្រើនដូចជា វេឡុវនារាម ជាវត្តធំជាងគេ វត្តតបោទារាម វត្តសត្តបណ្ណគុហារាម កស្សបារាម សីតវនារាម ជីវកម្ពវនារាម បាវារិការាម ឥន្ទសាលារាម កាឡសិលារាម លដ្ឋិវនារាម គោមតនិគ្រោធារាម វត្តភ្នំគិជ្ឈកូដ វត្តទក្ខិណាគិរី ឯកនាលា និង វត្តបាសាណកចេតិយ ជាដើម ។



# ក្រុងរាជគ្រឹះដែនមគធៈ

បន្ទាប់អំពីព្រះអង្គបានសាងផ្នួសហើយ មិនទាន់បានត្រាស់ដឹងជាព្រះពុទ្ធ ព្រះអង្គបាននិមន្តបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ មនុស្សទាំងអស់នាំគ្នាផ្អើលមើលព្រះ**បរមពោធិសត្វ** ដោយសេចក្តីពេញចិត្ត ព្រោះព្រះអង្គមានព្រះវរកាយ ប្រកបដោយព្រះ**មហាបុរិសលក្ខណៈ**ដ៏ប្រសើរ ។ **ព្រះបាទពិម្ពិសារ**ក៏បានយាងមកជួបព្រះពោធិសត្វដំបូងក្នុងទីនេះ ព្រះរាជាបានប្រគល់នូវរាជសម្បត្តិ ពាក់កណ្តាលថ្វាយព្រះពោធិសត្វ តែព្រះអង្គមិនទទួល ព្រោះព្រះអង្គជាបុគ្គលលះបង់រាជសម្បត្តិដើម្បីត្រាស់ជាព្រះពុទ្ធ ។ ផ្លូវដែលចាស់ខូងលើថ្មនេះ នៅក្នុងក្រុងរាជគ្រឹះបញ្ជាក់ឱ្យដឹងថា សម័យបុរាណមានមនុស្សជាច្រើនបានធ្វើដំណើរតាមផ្លូវនេះ ដោយរទេះគោទើបធ្វើឱ្យថ្មនេះ សឹកខូងគួរឱ្យចាប់អារម្មណ៍ និងសង្វេគទៅដល់សម័យនោះណាស់ ហើយគួរពិចារណាថា មនុស្សសម័យនោះ បានស្លាប់អស់ទៅហើយ ឃើញនៅសល់តែស្នាមដានជើងរទេះប៉ុណ្ណោះ ។

***"ការចិញ្ចឹមជីវិតជាការលំបាកក្រៃលែង"***

កន្លែងព្រះបរមពោធិសត្វ ជួបស្តេចពិម្ពិសារលើកដំបូង នៅជិតភ្នំបណ្ឌវៈ នៃនគររាជគ្រឹះដែនមគធៈ





ផ្លូវរទេះចាស់ខូង លើថ្មក្នុងក្រុងរាជគ្រឹះ







# ព្រះចេតិយជប៉ុនលើភ្នំ

ក្រុងរាជគ្រឹះមានភ្នំទាំង ៥ ព័ទ្ធព័ទ្ធដូចជា ភ្នំឥសិគិលិ ភ្នំវេភារៈ ភ្នំវេបុល្ល ភ្នំគិជ្ឈកូដ ភ្នំបណ្ឌវៈ សម័យពុទ្ធកាលក្រុងរាជគ្រឹះគ្រប់គ្រងដោយព្រះបាទពិម្ពិសារ និងព្រះបាទអជាតសត្តុ ទីក្រុងរាជគ្រឹះមានកិត្តិសព្ទល្បីល្បាញ ហើយមានមនុស្ស១៨០លាននាក់ រស់នៅក្នុងទីក្រុង







ជិះកន្ត្រកយន្តឡើងភ្នំទៅកាន់ព្រះចេតិយ





នេះព្រះសម្មាសម្ពុទ្ធបានគង់ប្រថាប់ ក្នុងព្រះគន្ធកុដិ លើភ្នំគិជ្ឈកូដជាដើម ព្រះអង្គសម្តែងធម៌ប្រោសដល់មនុស្សបានសម្រេចគុណធម៌ជាច្រើន ។

បច្ចុប្បន្នក្នុងទីក្រុងនេះ មិនមានព្រះរាជា សេដ្ឋីគហបតី ដូចសម័យពុទ្ធកាលទេ បានឃើញត្រឹមតែភ្នំដែលមិនសូវមានដើមឈើ ផ្លូវរទេះខូងលើថ្ម គួរឱ្យសង្វេគក្រៃពេក ។ ធ្វើដំណើរឡើងទៅលើកំពូលភ្នំ ពុទ្ធបរិស័ទយើងអាចជិះកន្ត្រកយន្ត ដើម្បីនមស្ការព្រះចេ-តិយ ដែលជប៉ុនកសាងយ៉ាងធំ ដែលមានពណ៌ស្អាត ។ នៅលើកំពូលភ្នំ យើងបានក្រឡេកឃើញទីក្រុងចាស់គួរឱ្យសង្វេគ ដូចព្រះអង្គត្រាស់ថា សង្ខារធម៌មិនទៀង ។

# ទិដ្ឋភាពក្រុងរាជគ្រឹះបច្ចុប្បន្ន



ទស្សនាក្រុងរាជគ្រឹះពីលើភ្នំគិជ្ឈកូដ




ព្រះគន្ធកុដិ មើលពីខាងក្រោម



ព្រះគន្ធកុដិ មើលពីខាងលើ



ឧ.ស ថា សុខុម និង ឧ.សិ ស៊ុន ឡុន

ភ្នំគិជ្ឈកូដនៅក្នុងក្រុងរាជគ្រឹះ ពាក្យថា គិជ្ឈកូដ មានន័យថា ភ្នំមានរាងដូចក្បាលសត្វត្មាត ភ្នំនេះមិនខ្ពស់ប៉ុន្មានទេ យើងអាចឡើងក្នុងរយៈពេលប្រហែលជិត ១ ម៉ោង ទើបទៅដល់ព្រះគន្ធកុដិ របស់ព្រះអង្គដែលនៅលើកំពូលភ្នំ ។ ពុទ្ធមាមិកជនមកពីបណ្តាប្រទេសនានាតែងតែមកថ្វាយបង្គំ ព្រះគន្ធកុដិនៅទីនេះដោយចិត្តជ្រះថ្លា ព្រោះថាទីនេះ មានប្រវត្តិកើតឡើងជាច្រើន នាសម័យពុទ្ធកាល ។



# ព្រះគន្ធកុដិលើភ្នំគិជ្ឈកូដ

លើភ្នំគិជ្ឈកូដមានព្រះគន្ធកុដិមួយរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ឥឡូវនៅសល់តែខឿន បន្តិចបន្តួចប៉ុណ្ណោះ ហើយមានកុដិព្រះអានន្ទ នៅជិតផងដែរ តាមផ្លូវឡើងមកព្រះគន្ធកុដិនៅខាងស្តាំដៃ យើងបានគោរពថ្វាយបង្គំកន្លែងព្រះមោគ្គល្លានត្ថេរ ធ្លាប់គង់នៅ បន្ទាប់មកទៀត ទស្សនាគុហាឈ្មោះ សូករខាតា ជាកន្លែងព្រះសារីបុត្ត សម្រេចជាព្រះអរហន្ត។


ព្រះគន្ធកុដិព្រះសម្មាសម្ពុទ្ធ 11 3 2006


កុដិព្រះអានន្ទ


សូករខាតាគុហា





ភិក្ខុទេវទត្តមានសេចក្តីច្រណែន នឹងព្រះសម្មាសម្ពុទ្ធ ថ្ងៃមួយទេវទត្តបានប្រមាលថ្មមួយដុំទម្លាក់ ដើម្បីធ្វើគុតព្រះអង្គ ទេវទត្តត្រូវអនន្តរិយកម្ម ។ព្រះមោគ្គល្លានបានឃើញប្រេតជាច្រើន នៅជើងភ្នំគិជ្ឈកូដនេះដូចជា អជគរប្រេត មំសបេសកប្រេត( មានសម្តែងក្នុងគម្ពីរធម្មបទ ទណ្ឌវគ្គ និង ព្រះវិន័យបិដក មហាវិភង្គ )។ ព្រះបាទពិម្ពិសារទ្រង់ធ្លាប់ស្តេចយាងឡើង ចុះភ្នំគិជ្ឈកូដដើម្បីស្តាប់ធម៌ព្រះអង្គ។


ដំណើរឡើងទៅព្រះគន្ធកុដិ


ព្រះមោគ្គល្លានធ្លាប់គង់នៅ

# ស្ទឹងតបោទា



អ្នកងូតលំដាប់ថ្នាក់លើ



អ្នកងូតទឹកក្ដៅ ដូចជាជណ្ដើមគ្នា





អ្នកងូតថ្នាក់ក្រោម



ព្រះដែលឥណ្ឌាពួកខ្លះគោរព





នៅជើងភ្នំវេភារៈ មានទឹកក្ដៅហូរមកជានិច្ច ហៅថា ស្ទឹងតបោទា ទឹកស្ទឹងហូរមកយ៉ាងនេះជាយូរមកហើយ ព្រះមោគ្គល្លានបានដឹងថា ខ្សែទឹកនេះហូរកាត់ លោហកុម្ភីនរក ទើបបានជាក្ដៅជានិច្ច ។ ជនជាតិឥណ្ឌាបច្ចុប្បន្ន មានជំនឿថា ជាទឹកមង្គលទើបបានមកងូតទឹកនេះ ជាច្រើននាក់ ហើយបានបែងចែកថ្នាក់លើ ថ្នាក់ក្រោមតាមវណ្ណៈមាន ក្រ ។ ទឹកក្ដៅដែលងូតច្រើននាក់បង្កទៅជាកន្លែងដែលមានក្លិនស្អុយ ព្រោះមិនមានការថែរក្សាឱ្យបានល្អ ។

# បិប្ផលិគុហាកន្លែងព្រះមហាកស្សប ធ្លាប់គង់នៅ

តាមផ្លូវឡើងពីស្ទឹងតបោទាទៅលើកំពូលភ្នំវេភារៈ នៅខាងស្តាំដៃនាចង្កេះភ្នំនេះ យើងបានទស្សនានូវបិប្ផលិគុហា ដែលជាកន្លែងព្រះមហាកស្សប ធ្លាប់បានគង់នៅ កាលនោះលោកមានអាពាធជាខ្លាំង ព្រះដ៏មានព្រះភាគបានយាងមកទីនេះសម្តែងពោជ្ឈង្គទាំង ៧ ដល់ព្រះមហាកស្សប ព្រះថេរៈស្តាប់ហើយបានជាពីអាពាធនោះទៅ( មានសម្តែងក្នុងគម្ពីរសំយុត្តនិកាយ កស្សបសំយុត្ត) បិដកលេខ ៣៧ ទំព័រ២០៥ ។







ជណ្តើរឡើងភ្នំវេភារៈ





បិប្ផលិគុហាព្រះកស្សបៈធ្លាប់គង់នៅ មើលពីខាងក្រោម

# ភ្នំវេភារៈកន្លែងធ្វើបឋមសង្គាយនា

ព្រះអង្គបរិនិព្វានទៅបាន ៣ខែ ព្រះមហាកស្សបបានដឹកនាំ ភិក្ខុសង្ឃ ៥០០ អង្គ មានព្រះឧបាលី និងព្រះអានន្ទជាដើមធ្វើ សង្គាយនា គឺការប្រមូលធម៌វិន័យទុកដាក់ដើម្បីជាប្រយោជន៍ ដល់ទេវតា និងមនុស្សជំនាន់ក្រោយ ។ ព្រះបាទអជាតសត្តុបាន រៀបចំកន្លែងធ្វើសង្គាយនា លើភ្នំវេភារៈ ក្នុងសត្តបណ្ណគុហា គឺរៀបចំទីនេះ បានយ៉ាងស្អាតបាក់បីដូចជាឋានទេវលោក ។ ការសង្គាយនានេះ បានប្រព្រឹត្តទៅអស់រយៈពេល ៧ខែ ទើប សម្រេច ផែនដីក៏កម្រើកញាប់ញ័រ ( មានពិស្តារក្នុងវិន័យបិដកលេខ ១១ ) ។



ខាងមុខសត្តបណ្ណគុហា













សត្តបណ្ណគុហា



ក្នុងសត្តបណ្ណគុហា

# វត្តជីវកម្ពវ័ន







ក្នុងក្រុងរាជគ្រឹះ មានលោកគ្រូពេទ្យម្នាក់ ឈ្មោះ ជីវកកោមារភច្ច កើតនៅក្នុងរាជគ្រឹះ ម្តាយជាស្រីសោភិនីឈ្មោះ សាលវតី ហើយ មានប្អូនស្រីម្នាក់គឺ នាងសិរិមា គ្រូពេទ្យ កោមារភច្ច ត្រូវម្តាយបោះបង់តាំងពីកើត មក មានបិតាចិញ្ចឹមឈ្មោះ អភយរាជកុមារ ពេលធំឡើងបានរៀនវិជ្ជាពេទ្យ នៅឯនគរ តក្កសិលា បានចេះចាំយ៉ាងស្ទាត់ជំនាញខាង ព្យាបាលរោគ ពេទ្យនោះបានស្តាប់ធម៌លើភ្នំ គិជ្ឈកូដ បានសម្រេចជា សោតាបន្នបុគ្គល ហើយបានវេរនូវចំការស្វាយរបស់គាត់ថ្វាយ ចំពោះព្រះសម្មាសម្ពុទ្ធ និង ភិក្ខុសង្ឃ ដែល មានឈ្មោះថា ជីវកម្ពវ័ន នៅក្បែរជើងភ្នំ គិជ្ឈកូដ ក្នុងក្រុងរាជគ្រឹះព្រះអង្គធ្លាប់គង់ នៅក្នុងទីនោះ ( ឥឡូវឃើញត្រឹមតែខឿន បន្តិចបន្តួចប៉ុណ្ណោះ ) សង្ខារធម៌ទាំងឡាយ ពិតជាមិនទៀងមែនហ្ន៎! ។ មានពិស្តារក្នុង វិន័យបិដកលេខ ៦ ទំព័រ ២៣៩ និងបិដក លេខ ១០ ទំព័រ ១៦៩ និងបិដកលេខ ២៣ ទំព័រ ៨៣ ។

# វាំងចាស់នៃនគររាជគ្រឹះ



    

នេះគឺជារូបភាពនៃវាំងចាស់នគររាជគ្រឹះសម័យបុរាណ ឥឡូវយើងឃើញមានតែស្លាកឥដ្ឋ បន្តិចបន្តួចប៉ុណ្ណោះ ។ ប៉ុន្តែបានស្តាប់ថា ទីនេះហើយដែលព្រះបាទពិម្ពិសារ បានធ្វើទានចំពោះព្រះពុទ្ធ និងភិក្ខុសង្ឃ ឧទ្ទិសចំពោះពពួកញាតិ ដែលកើតក្នុងកំណើតជាប្រេត ហើយព្រះអង្គបានសម្តែង តិរោកុឌ្ឌសូត្រនៅទីនេះ ។

**ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។**

វីបុណ្យកុសលនេះសូមឧទ្ទិសចំពោះញាតិ សូមញាតិទាំងឡាយ ចូរជាអ្នកដល់នូវសេចក្តីសុខចុះ ។

# ឃ្លាំងទ្រព្យសម្បត្តិព្រះបាទពិម្ពិសារ


ក្នុងឃ្លាំងទ្រព្យ


ទ្វារចូល

នៅទីងជើងភ្នំរាជគ្រឹះជិតវាំងចាស់ មានគុហាថ្មធំល្មម ដែលគេដាប់ចោះធ្វើជាឃ្លាំង សម្រាប់ផ្ទុកទ្រព្យសម្បត្តិរបស់ព្រះរាជាសម័យនោះ។ នឹកជ្រះថ្លាចំពោះព្រះបាទពិម្ពិសារបរិច្ចាគទ្រព្យកសាងវត្តវេឡុវ័ន មានការកសាងព្រះគន្ធកុដិជាដើម និងទំនុកបំរុងភិក្ខុសង្ឃ ។ ទិដ្ឋភាពនៅពេលបច្ចុប្បន្ន បញ្ជាក់ថា អ្វីៗ ក្នុងលោករមែងប្រែប្រួលអស់ទៅសូន្យទៅ គួរខំសន្សំបុណ្យអប់រំចិត្ត។

**សម្បត្តិជាគូ នឹងវិបត្តិ**



# គុកឃុំឃាំងព្រះបាទពិម្ពិសារ








ព្រះបាទពិម្ពិសារ ជាអរិយបុគ្គល ស្តេចនៃនគររាជគ្រឹះនេះ ដោយអកុសល មានរាជបុត្រមិនប្រកបដោយធម៌គឺអជាតសត្តុកុមារកាលរាជបុត្រ បានឡើងសោយរាជ្យ ដោយជឿតាមពាក្យញុះញង់របស់ទេវទត្ត ក៏យកបិតារបស់ខ្លួនដាក់ពន្ធនាគាររហូតបិតាសោយទិវង្គត នៅក្នុងគុកនេះ ក្នុងព្រះជន្ម ៦៧ ព្រះវស្សា។ ពន្ធនាគារនេះ នៅជិតភ្នំគិជ្ឈកូដក្នុងក្រុងរាជគ្រឹះ "គួរសង្វេគចំពោះតណ្ហារបស់សត្វលោក "។


ព្រះបាទពិម្ពិសារសោយទិវង្គតក្នុងគុកនេះ

# វត្តវេឡុវ័ន  កលន្ទកនិវាបស្ថាន





ព្រះបរមសាស្តាចារ្យ បានគង់ចាំវស្សានៅក្នុងវត្តវេឡុវ័នជាច្រើនវស្សា ផងដែរគឺវស្សាទី២, ៣, ៤, ១៧ និងទី២០ សម្តែងធមិជាច្រើនក្នុងវត្តនេះ។

- ជាកន្លែងធ្វើការប្រជុំចតុរង្គសន្និបាត
- ព្រះអង្គសម្តែងឱវាទបាតិមោក្ខដល់ភិក្ខុ ១២៥០អង្គ
- ព្រះអង្គទ្រង់ស្ថាបនាអគ្គសាវ័កទាំងពីររបស់ព្រះអង្គ
- ព្រះសារីបុត្ត និងព្រះមោគ្គល្លានបានបួសជាឯហិភិក្ខុឧបសម្បទា
- ព្រះនាងខេមាភិក្ខុនី បានសម្រេចជាព្រះអរហន្តី
- ព្រះអញ្ញាកោណ្ឌញ្ញៈថ្វាយបង្គំលាព្រះសាស្តា ដើម្បីចូលបរិនិព្វាន

ព្រះបាទពិម្ពិសារ  បានថ្វាយនូវឧទ្យាននេះ ចំពោះព្រះសាស្តាចារ្យមុនដំបូងបំផុត ក្នុងព្រះពុទ្ធសាសនា វត្តវេឡុវ័ន នៅក្បែរក្រុងរាជគ្រឹះ ។ ។



**វត្តវេឡុវ័ន** ប្រែថាៈ  វត្តដែលមានដើមឫស្សី

**កលន្ទកនិវាបស្ថាន** ប្រែថាៈ កន្លែងឱ្យអភ័យ ដល់សត្វកង្ហែន

# វត្តវេឡុវ័នបច្ចុប្បន្ន


សម្តែងឱវាទបាតិមោក្ខ


អង្គុយស្តាប់ធម៌ក្នុងវត្តវេឡុវ័ន


ស្រះទឹកក្នុងវត្តវេឡុវ័ន

ពុទ្ធបរិស័ទយើងមកដល់ទីនេះ បានឃើញវត្តវេឡុវ័ន សព្វថ្ងៃមិនមានព្រះសង្ឃគង់នៅ មិនមានកុដិ សាលា វិហារឡើយ ។ ទីនេះមានដើមឫស្សីជាច្រើន ហើយឃើញស្រះទឹកមួយធំ នៅកណ្តាលវត្ត ជុំវិញស្រះទឹកគេរៀបជាផ្លូវដើរយ៉ាងល្អ មានដើមប្រេងខ្យល់ដាំដុះជាជួរគួរឱ្យរីករាយ ។




រូបភាពកែច្នៃ

## ឱវាទបាតិមោក្ខសង្ខេប

*សព្វបាបស្ស អករណំ កុសលស្សូបសម្បទា*
*សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។*

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។



ខ្លោងទ្វារវត្តវេឡុវ័នបច្ចុប្បន្ន

លោកគ្រូធម្មាចារ្យ
គាំ អ៊ីច



**ពិចារណាថា** កាលនោះព្រះសម្មាសម្ពុទ្ធគង់នៅ មានភិក្ខុសង្ឃចោមរោម និង ពុទ្ធបរិស័ទនៅនាក្រុងរាជគ្រឹះនេះ មកគាល់ដើម្បីស្តាប់ធមិ តែឥឡូវក៏ស្ងប់ស្ងាត់ទទេ គួរឱ្យសង្វេគណាស់ ។

# ព្រះចេតិយធាតុនិធាន

នៅជិតវត្តវេឡុវ័ន មានព្រះចេតិយមួយ ដែលព្រះបាទអជាតសត្តុបានកសាងសម្រាប់តម្កល់ ព្រះបរមសារីរិកធាតុ ដែល ព្រះមហាកស្សបត្ថេរ បានប្រមូលមកគ្រប់ទីកន្លែងវៀរលែងរាមគ្រាម តម្កល់ក្នុងព្រះចេតិយ មានជម្រៅទៅក្រោមដី ៨០ហត្ថ ប្រតិស្ឋានទុកបានយ៉ាងល្អ ដែលព្រះមហាកស្សបត្ថេរតម្កល់ទុកដើម្បីជាប្រយោជន៍ ដល់ព្រះបាទ



គ្រឹះចេតិយចាស់

ធម្មាសោក ដែលត្រូវសោយរាជសម្បត្តិ ក្នុងព.ស. ២១៨ឆ្នាំ។ មកដល់សម័យ ព្រះបាទធម្មាសោក ព្រះអង្គ បានយកព្រះបរមសារីរិកធាតុទាំងអស់នេះ ធ្វើបុណ្យយ៉ាងធំនៅជម្ពូទ្វីប ហើយបែងចែកព្រះធាតុទៅគ្រប់ទីកន្លែង "ព្រះចេតិយធាតុនិធានគួរឱ្យជ្រះថ្លា"។





ខឿនចេតិយមើលពីចម្ងាយ

# ភ្នំកុក្កុដសមបាត ព្រះមហាកស្សបបរិនិព្វាន



ប្រកឡើងភ្នំមានផ្ទាំងថ្មសងខាង

នៅក្បែរក្រុងរាជគ្រឹះមានភ្នំមួយឈ្មោះ កុក្កុដសមបាត ដែលជាទីកន្លែងព្រះមហាកស្សបបរិនិព្វាន។ ព្រះមហាកស្សប គឺជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ កំពូលលើសភិក្ខុទាំងឡាយផ្នែកខាងធុតង្គ ព្រះសម្មាសម្ពុទ្ធបរិនិព្វានទៅ លោកបានដឹកនាំភិក្ខុសង្ឃធ្វើសង្គាយនាតមកទៀតបានប្រមូលព្រះបរមសារីរិកធាតុពីគ្រប់ទីកន្លែង (វៀរលែងតែរាមគ្រាម) មកប្រតិស្ឋានក្នុងក្រុងរាជគ្រឹះ ដើម្បីជាប្រយោជន៍ដល់បរិស័ទសម័យក្រោយ ។








កាលលោកមាន ព្រះជន្មគ្រប់ ១២០ វស្សា លោកបានបរិនិព្វាននៅភ្នំកុក្កុដសមបាតនេះ ដោយលោកសម្ដែងឫទ្ធិ ញុំាងភ្នំទាំង ៣ អោយទៅជាភ្នំមួយ ព្រះសពរបស់លោកនៅខាងក្នុងផ្ទាំងថ្មធំ មនុស្សយើងមិនអាចមើលឃើញព្រះសពរបស់លោកបានទេ ព្រះសពនោះនឹងត្រូវបានបូជានាសម័យនៃព្រះពុទ្ធអរិយមេត្តេយ្យ ។

# ភ្នំកុក្កុដសមបាត



ព្រះបដិមាព្រះកស្សបក្នុងរូងភ្នំ



ចេតិយលើភ្នំទើបតែកសាង

ភ្នំកុក្កុដសមបាត សព្វថ្ងៃជាបូជនីយដ្ឋានដ៏ពិសេស ដែលពុទ្ធបរិស័ទគ្រប់ប្រទេស តែងមកថ្វាយបង្គំធ្វើដំណើរពីពុទ្ធគយាមកប្រហែលជាង ២ម៉ោង ទើបមកដល់ឡើងភ្នំនេះ ចំណាយពេលជិត ៣ម៉ោង ។ ខាងលើកំពូលភ្នំមានព្រះចេតិយ និង រូបបដិមាក្នុងគុហាគួរអោយជ្រះថ្លា និង សង្វេគដ៏ក្រៃលែង ។





ចង្អូរផ្លូវលើភ្នំកុក្កុដសមបាត









ផ្លូវឡើងភ្នំកុក្កុដសមបាត



ធ្វើដំណើរឡើងភ្នំដោយចិត្តជ្រះថ្លា

# សាកលវិទ្យាល័យនាលន្ទា



សាកលវិទ្យាល័យស្ថិតនៅក្នុងស្រុកនាលន្ទា សព្វថ្ងៃហៅថា ស្រុកសារីចក្រ ដែលជាស្រុកកំណើតរបស់ព្រះសារីបុត្ត មានចម្ងាយ ១៦គ.ម.ពីក្រុងរាជគ្រឹះ។ ក្រោយពីព្រះសម្មាសម្ពុទ្ធបរិនិព្វានទៅជាច្រើនឆ្នាំ មានព្រះរាជាមួយព្រះអង្គ បានរៀបចំកន្លែងសិក្សារបស់សមណសិស្សគឺ បានធ្វើសាលារៀនយ៉ាងធំក្នុងសតវត្សទី១២ បរិវេណសាលានេះមានទំហំ១០គ.ម. បួនជ្រុងមានគ្រូបង្រៀន ២ពាន់នាក់ និង សិស្សចំនួន ១ ម៉ឺននាក់ សម័យក្រោយមក ត្រូវសាសនាហិណ្ឌូ បានមកដុតបំផ្លាញទីនេះឆេះរហូត ៦ខែ ទើបអស់ គេកសាងសាកលវិទ្យាល័យនាលន្ទាថ្មី នៅក្បែរគ្នា។ សម័យពុទ្ធកាលទីនេះគឺ វត្តបាវារិកម្ពវ័ន (បាវារិកសេដ្ឋីកសាង)។


















ពុទ្ធបរិស័ទសម័យនោះ បានកសាងព្រះចេតិយ តម្កល់ព្រះធាតុ របស់ព្រះសារីបុត្តក្នុងសាកលវិទ្យាល័យនេះ ដោយគិតថាជាស្រុក កំណើតរបស់លោក សព្វថ្ងៃព្រះចេតិយបានបាក់បែកខ្លះហើយ ។







លោកគ្រូ រាម រដ្ឋា នៅកំពង់សោម







# កន្លែងព្រះសារីបុត្តប្រសូត និង បរិនិព្វាន

ព្រះសារីបុត្តកំពូលលើសភិក្ខុទាំងឡាយ ផ្នែកខាងបញ្ញា លោកមានស្រុកកំណើត នៅនាលន្ទា មាតាឈ្មោះ **សារីព្រាហ្មណី** បិតាឈ្មោះ **វង្គន្តព្រាហ្មណ៍** ជាមេស្រុក





សាងសង់តំណាងផ្ទះព្រះសារីបុត្ត





ព្រះថេរៈមានបងប្អូន ៧នាក់ លោកជាបុត្រច្បងគេ ។ មានពុទ្ធបរិស័ទជាច្រើនជ្រះថ្លានឹងលោក ព្រះថេរៈ បានបរិនិព្វានក្នុងផ្ទះដែលលោកប្រសូត ដើម្បីអនុគ្រោះដល់មាតា ។ សព្វថ្ងៃមានដើមត្នោត ឫស្សីជាដើម ក្នុងស្រុករបស់លោកគួរឱ្យនឹកស្រណោះ (ទីនេះនៅខាងទិសបូព៌ា នៃសាកលវិទ្យាល័យនាលន្ទា ចម្ងាយជាង ២ គ.ម. ) ។

## ភូមិគ្រឹះចាស់របស់ព្រះមោគ្គល្លាន



ព្រះមោគ្គល្លាន ជាអគ្គសាវ័កឆ្វេង មាតាឈ្មោះមោគ្គល្លីព្រាហ្មណី ក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងកោលិតនិគម មិនឆ្ងាយពីក្រុងរាជគ្រឹះ លោកជាសម្លាញ់របស់ព្រះសារីបុត្ត បានចេញបួសជាមួយគ្នា លោកបរិនិព្វាននៅភ្នំកាឡគិរី ។

# វត្តអសោការាម

ព.ស. ២១៨ មានព្រះមហាក្សត្រ មួយព្រះអង្គគឺ ព្រះបាទធម្មាសោក ជាស្តេចមានអំណាចមានរាជទ្រព្យ ច្រើន ទ្រង់នៅក្នុងនគរបាដលិបុត្រ សព្វថ្ងៃហៅថា បតនះ នៅក្នុងរដ្ឋ ពិហារ នៃប្រទេសឥណ្ឌា មាន ចម្ងាយ ១០២គ.ម. ពីរាជគ្រឹះ,៥៥ គ.ម. ពីវេសាលី, ១០១៥ គ.ម. ពី ញូវដែលី, ព្រះអង្គបានជ្រះថ្លាក្នុង ព្រះពុទ្ធសាសនា ឧបត្ថម្ភព្រះភិក្ខុ សង្ឃកសាងវត្តអារាម ព្រះចេតិយ ៨៤០០០ចេតិយ បូជាបុត្រា បុត្រី គឺព្រះមហិន្ទ និងព្រះនាងសង្ឃមិត្តា ឱ្យបួសក្នុងព្រះពុទ្ធសាសនា។ ព្រះអង្គ កសាងវត្តយ៉ាងធំមួយនៅ ក្នុងក្រុងបាដលិបុត្រ វត្តនេះហៅ ថាអសោការាមកើតក្នុង ព.ស.ជាង


ទីធ្លាក្នុងវត្តអសោការាម





២០០ឆ្នាំ។ សម័យនោះមានភិក្ខុសង្ឃគង់នៅ ៦ម៉ឺន អង្គ ក្នុងវត្តនេះ មានព្រះមោគ្គលីបុត្តតិស្សត្ថេរ ជា ប្រធាន។





# សង្គាយនាលើកទី ៣ ក្នុងវត្តអសោការាម

ក្នុង ព.ស.២៣៤ ព្រះមោគ្គ-លីបុត្តតិស្សត្ថេរ បានជ្រើសរើស ព្រះសង្ឃក្នុងចំណោម ៦ លានអង្គ យកតែ ១ពាន់អង្គ ដែលជាព្រះអរហន្ត ដែលទ្រទ្រង់ព្រះត្រៃបិដក មានបដិសម្ភិទាញាណ ។



សសរស្តម្ភបានដួលដេកទៅហើយ









ធ្វើតតិយសង្គាយនាប្រព្រឹត្តទៅ ៩ខែទើបសម្រេច សង្គីតិកម្មចប់ពេលណា ប្រឹថពីកម្រើកញាប់ញ័រ ។ អសោការាម បច្ចុប្បន្នមានសសរស្តម្ភ ដែលកសាងឡើងដោយព្រះបាទធម្មាសោក ដើម្បីចំណាំថា ទីនេះវត្តអសោការាម បច្ចុប្បន្ននេះមិនមានព្រះសង្ឃទេ ទីនេះជាបូជនីយដ្ឋាន គួរគោរពបូជា នឹងគួរនឹកស្រណោះសង្វេគ ។

# រូបភាពគ្រឹះវាំងចាស់បច្ចុប្បន្ននៃវេសាលី





ទីក្រុងវេសាលីសព្វថ្ងៃហៅថា ពេសារហ៏ នៅក្នុងរដ្ឋ **បិហារ** មានចម្ងាយ ៥៥ គ.ម. ពីទីក្រុងបតនៈ (បាដលិបុត្រ) នៅពីក្រោយវេសាលីមានព្រៃឈ្មោះ **មហាវ័ន**។ រូបភាពទាំងនេះ គឺជាគ្រឹះវាំងចាស់នៃនគរវេសាលី សម័យពុទ្ធកាលនគរនេះគ្រប់គ្រងរាជសម្បត្តិ ដោយស្តេច**លិច្ឆវី** កាលនោះ




អន្តរាយ ៣ប្រការកើតឡើងគឺកើតទុរភិក្សកើតអាសន្នរោគ និង អមនុស្សបៀតបៀន ។ ស្តេចលិច្ឆវី អារាធនានិមន្តព្រះបរមសាស្តាចារ្យ ព្រះអង្គស្តេចយាងមកនគរនេះដោយកម្លាំងនៃពុទ្ធានុភាព បានញុាំងនគរវេសាលី ឱ្យមានភ្លៀងធ្លាក់ជាប្រក្រតីឡើងវិញ មនុស្សបានជារោគទាំងឡាយ អមនុស្សក៏រត់ចេញអស់ទៅ ។ ព្រះតថាគតទ្រង់សម្តែង ព្រះរតនសូត្រ មនុស្សស្តាប់ហើយ បានសម្រេចធម៌ ៨៤000 រូប ។ ព្រះសង្ឃខ្មែរយើង និង ពុទ្ធបរិស័ទមកសូធ្យធម៌ រំលឹកគុណ កាលព្រះអង្គ ធ្លាប់ស្តេចយាងមកវេសាលីលើកដំបូងសម្តែងរតនសូត្រ។ ក្រោយបានស្តាប់ប្រវត្តិនៃនគរវេសាលី គួរឱ្យជ្រះថ្លា និង សង្វេគតក់ស្លុត។



# ស្រះទឹកមង្គលក្នុងនគរវេសាលី



សម័យកាលនោះ ស្តេចលិច្ឆវី បានសន្មតស្រះមួយជាស្រះមង្គល ព្រោះមានទឹកថ្លាស្អាតគួរជាទីរីករាយ ស្រះនេះនៅជិតអម្ពបាលិវ័ន ព្រៃស្វាយរបស់នាងអម្ពបាលី ។ សព្វថ្ងៃយើងឃើញមានវត្តជប៉ុនមួយ បានកសាងព្រះចេតិយពណ៌សយ៉ាងធំនៅជិតស្រះទឹកនេះ ។ នៅវេសាលីមានវត្តជាច្រើនដូចជា វត្តជប៉ុន វត្តវៀតណាម វត្តថៃ ហើយមានវត្តខ្មែរដែលទើបតែកសាងដោយព្រះភិក្ខុ **ញើយ មេត្តា** វត្តខ្មែរវេសាលី គួរជាទីជ្រះថ្លាកើតឡើងដោយកម្លាំងសទ្ធាចូលរួមនៃពុទ្ធបរិស័ទខ្មែរយើង (វត្តខ្មែរនៅខាងកើតស្រះមង្គលនេះ ប្រហែលជាង ១០០០ ម៉ែត្រ) ។











# អម្ពបាលិវ័ន(ព្រៃស្វាយ)



គ្រឹះចេតិយចាស់





ក្នុងសម័យពុទ្ធកាល
មានស្ត្រីម្នាក់បានកើតពីដើមស្វាយ គេបានដាក់
ឈ្មោះឱ្យនាងថា អម្ពបាលី ដោយនាងមានរូបសម្បត្តិល្អជាពន់ពេក
ទើបព្រះរាជាបានឱ្យនាងធ្វើជា ស្រីសោភិនី (ស្រីផ្កាមាស) ដោយអកុសលពីបុព្វជាតិ ។
កាលព្រះពុទ្ធជាម្ចាស់យាងទៅកាន់នគរវេសាលី នាងបានស្តាប់ធម៌កើតសេចក្តីជ្រះថ្លា បានវេរនូវចម្ការស្វាយរបស់នាងចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដូច្នេះទីនេះមានឈ្មោះថា វត្តអម្ពបាលិវ័ន ក្រោយមកទៀតនាងមានកូនជាមួយព្រះបាទពិម្ពិសារ កូននោះបានបួសសម្រេចជា ព្រះអរហន្ត នាងក៏បានបួសហើយបានសម្រេចជាព្រះអរហន្តី ។

បិដកលេខ៥៧ ទំព័រ១៩៥ អម្ពបាលីថេរី គាថាខាងចុងព្រះនាងពោលថា ***ឯទិសោ អហុ អយំ សមុស្សយោ***
***ជជ្ជរោ ពហុទុក្ខានមាលយោ***
***សោបលេបបតិតោ ជរាឃរោ***
***សច្ចវាទិវចនំ អនញ្ញថា ។***

ប្រែថា គ្រោងកាយ មានសភាពដូច្នេះនេះ គ្រាំគ្រា ជាលំនៅនៃសេចក្តីទុក្ខច្រើនប្រការ គ្រោងកាយនោះដូចជាផ្ទះចាស់ដែលមានគ្រឿងបូកលាបជ្រុះចុះ ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។

# ព្រះចេតិយចាស់ធ្លាប់តម្កល់ព្រះធាតុ ២នាឡិ ក្នុងអម្ពបាលិវ័ន



ពុទ្ធបរិស័ទថតរូបអនុស្សាវរីយ៍ដើម្បីទុកជាទីនឹករលឹក

កាលព្រះលោកនាថ ទ្រង់បរិនិព្វានទៅ ព្រះធាតុ ២នាឡិ បាននាំយកមកតម្កល់ទុកក្នុងព្រះចេតិយ ដែលកសាងក្នុងវត្តអម្ពបាលិវ័ន។ សព្វថ្ងៃ ព្រះចេតិយបានបាត់បង់ទៅហើយ សល់តែគ្រឹះបន្តិចបន្តួច គេធ្វើដំបូលស័ង្កសីគ្របពីលើព្រះចេតិយចាស់។



ផ្លូវចូលទៅព្រះចេតិយ

# ស្រុកភូមិបច្ចុប្បន្ននៃវេសាលី





ផ្លូវក្នុងភូមិ





អាចម៍គោហាលលក់





ពេលវេលាកន្លងទៅមិនសម្រាកមិនឈប់ឈរ បានញ៉ាំងឱ្យទីក្រុងវេសាលីទាំងអស់សាបសូន្យ បច្ចុប្បន្នអ្នកស្រុកនេះ ធ្វើកសិកម្មដូចជាធ្វើស្រែ ធ្វើចំការពោត ចំការចេក និងចិញ្ចឹមគោយកទឹកដោះ ហើយនឹងលក់អាចម៍គោ។

*កម្មុនា វត្តតី លោកោ*

សត្វលោកប្រព្រឹត្តទៅតាមកម្ម។

# កូដាគារសាលាមហាវ័ន



ធ្វើដំណើរចូលទៅកូដាគារសាលា

បិដកលេខ១១ ទំព័រ២៦២ (សេចក្ដីសង្ខេប)

ព្រះនាងមហាបជាបតីគោតមី បួសជាភិក្ខុនីក្នុងកូដាគារសាលា នាមហាវ័ននេះ មានប្រវត្តិថាកាលព្រះបាទសិរីសុទ្ធោទនៈពុទ្ធបិតាបរិនិព្វានទៅ ព្រះនាងមហាបជាបតីគោតមី ដែលត្រូវជាព្រះមាតុច្ឆារបស់ព្រះសាស្ដា ព្រះនាងមានសេចក្ដីជ្រះថ្លាជាខ្លាំង ចង់សាងបព្វជ្ជាទើបចូលទៅវត្តនិគ្រោធារាម (នៅកបិលពស្ដុ) សូមព្រះដ៏មានព្រះភាគ អនុញ្ញាតឱ្យស្ត្រីបានបួស តែកាលនោះ ព្រះអង្គមិនអនុញ្ញាតឱ្យស្ត្រីបួសឡើយ។ ក្រោយមក ព្រះសាស្ដាគង់នៅកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ព្រះនាងបជាបតីគោតមី ព្រមដោយ សាកិយានី ៥០០អង្គ ពេញចិត្តក្នុងការបព្វជ្ជានាំគ្នាកោរសក់ទ្រទ្រង់សំពត់កាសាវ័កធ្វើដំណើរចេញពីក្រុងកបិលពស្ដុ មកកាន់កូដាគារសាលាមាន៥១យោជន៍។ ព្រះនាងទ្រង់ព្រះកន្សែងហូរទឹកភ្នែក ព្រោះព្រះអង្គមិនអនុញ្ញាតឱ្យស្ត្រីបួស កាលនោះព្រះអានន្ទឃើញដូច្នេះ ទើបចូលគាល់ ព្រះសាស្ដាពោលសរសើរគុណ នៃព្រះនាងយ៉ាងច្រើន ហើយពោលទៀតថា សូមព្រះអង្គអនុញ្ញាត ឱ្យព្រះនាងបួសផងចុះ។ ព្រះអង្គត្រាស់ថា បើស្ត្រីទទួលនូវគរុធម៌ ៨ប្រការ តថាគត ឱ្យបួស។ ព្រះនាងបានបួសជាភិក្ខុនីមុនភិក្ខុនីទាំងឡាយ ដោយគរុធម៌៨ ក្នុងកូដាគារសាលា ។ ព្រះបរមលោកនាថទ្រង់គង់ចាំព្រះវស្សាទី៥ ក្នុងកូដាគារសាលា នាមហាវ័ននេះផងដែរ។



## ពិចារណា

នៅក្នុងលោកនេះមិនទៀង មានការប្រែប្រួលជានិច្ច។ ព្រះអង្គធ្លាប់គង់នៅ ឥឡូវស្ងាត់ឈឹង មិនឃើញស្រមោល ទីស្ថានដែលសេសសល់ក៏ត្រូវប្រែប្រួលទៀត កើតចាស់ឈឺស្លាប់បន្តគ្នា ព្រះនិព្វាន ជាស្ថានល្អក្រៃលែង ។

# កូដាគារសាលាព្រៃមហាវ័ន



កូដាគារសាលានាព្រៃមហាវ័ន គួរឱ្យជ្រះថ្លារបស់ពុទ្ធបរិស័ទ





សព្វថ្ងៃ យើងមើលឃើញព្រះចេតិយឈ្មោះថា អានន្ទចេតិយ ដែលអ្នកនគរទាំងអស់បាន កសាងបូជាចំពោះ ព្រះអានន្ទ ដើម្បីបូជាគុណ ដែលព្រះអានន្ទបានសុំអនុញ្ញាតឱ្យមានភិក្ខុនី ចេតិយនេះមានខឿនឥដ្ឋយ៉ាងច្រើននៅក្បែរសសរស្តម្ភព្រះបាទធម្មាសោកមហារាជ ។



ផ្លូវដើរជុំវិញកូដាគារសាលា



# សសរស្តម្ភ

សសរស្តម្ភនៅទីនេះ រឹងមាំ ជាងសសរនៅគ្រប់ទីទាំងពួង ព្រោះនៅឈរត្រង់គួរឱ្យជ្រះ ថ្លាចំពោះព្រះបាទធម្មាសោក យ៉ាងក្រៃលែង ដែលបានធ្វើ សសរដើម្បីចំណាំសម្រាប់ជន ជំនាន់ក្រោយ "សសរថ្មសុទ្ធ ដែលមានរូបសីហៈ នៅពីលើ បែរមុខទៅទិសខាងជើង"។



សសរស្តម្ភមានកម្ពស់ជាង ១២ម៉ែត្រ, ទម្ងន់ជាង ៥៥តោន



យើងទាំងអស់គ្នាជ្រះថ្លាណាស់បានមកដល់ទីនេះ

# ព្រះអង្គដាក់អាយុសង្ខារថ្ងៃ១៥កើត ខែមាឃ

មានក្នុងសុត្តន្តបិដកទីឃនិកាយ មហាបរិនិព្វានសូត្រ (លេខ១៦ ទំព័រ២១៥)។ មុនពេលព្រះអង្គបរិនិព្វាន ៣ខែ ក្នុងថ្ងៃ ១៥កើត ខែមាឃ ព្រះអង្គគង់នៅបាវាលចេតិយជិតក្រុងវេសាលី មារមកអារាធនា ព្រះអង្គចុងក្រោយថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គបរិនិព្វានទៅ កាលនេះជាកាលគួរនឹងព្រះអង្គបរិនិព្វានហើយ ។ ព្រោះថា ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា និង ទេវតា ជាអ្នកគួរយល់ដឹង អាចសំម្តែងធម៌ប្រកបដោយបាដិហារ្យបានហើយ ដូច្នេះ សូមព្រះអង្គបរិនិព្វានចុះ។ ព្រះមហាលោកនាថទ្រង់មិនញាប់ញ័រ ឆ្លើយតបវិញថា -



*<u>អប្បោស្សុក្កោ ត្វំ បាបិម ហោហិ ន ចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ</u>* ។

ប្រែថា: ម្នាលមារមានចិត្តបាប អ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ មិនយូរឡើយ ៣ខែទៀត តថាគតនឹងបរិនិព្វានហើយ ។ កាលនោះឯង មហាប្រឹថពី បានកម្រើកញាប់ញ័រ ។



# ឱវាទថ្ងៃ ១៥កើត ខែមាឃ

បន្ទាប់អំពីព្រះអង្គដាក់អាយុសង្ខារហើយ ព្រះអង្គឱ្យព្រះអានន្ទ ប្រជុំភិក្ខុសង្ឃ ក្នុងកូដាគារសាលានាមហាវ័ននេះ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយនេះ គប្បីតាំងនៅអស់កាលជាអង្វែង ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និង មនុស្សទាំងឡាយ ។ ធម៌ដែលតថាគតសម្តែងហើយ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេពចម្រើនធ្វើឱ្យរឿយៗ ធម៌នោះគឺអ្វីខ្លះ? គឺ សតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពលៈ៥ ពោជ្ឈង្គ៧ អរិយមគ្គប្រកបដោយអង្គ៨ ម្នាលភិក្ខុទាំងឡាយ តថាគតដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយមានសេចក្តីវិនាសជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឱ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ កន្លងទៅ ៣ខែទៀតតថាគតនឹងបរិនិព្វានហើយ ។

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះតែងមានសេចក្តីស្លាប់នៅខាងមុខ។ ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយទោះបី តូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វលោកទាំងឡាយ ក៏យ៉ាងនោះដែរ។ ព្រះសាស្តា ទ្រង់មានព្រះបន្ទូលដូច្នេះ តទៅទៀតថា វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគត មានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយហើយ ទៅឯទីពឹងចំពោះខ្លួនតថាគត បានធ្វើទុកហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួន ឱ្យរឿយៗចុះ ។ ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ ( ភិក្ខុនោះ ) នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះបរិនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខានឡើយ ។ ( បិដកលេខ ១៦ទំព័រ ២៥៣)



កូដាគារសាលាមហាវ័នជិតក្រុងវេសាលី

# នគរសាវត្ថី

## សេចក្ដីសង្ខេប

នគរសាវត្ថី ជានគរដែលល្បីល្បាញ សម័យពុទ្ធកាល គ្រប់គ្រងដោយព្រះបាទ បសេនទិកោសល មានមនុស្សចំនួន ៧០ កោដិ, ជាព្រះអរិយបុគ្គល ៥០កោដិ, ជាបុថុជ្ជន ២០កោដិ មានសេដ្ឋី និង គហបតីជាច្រើន សព្វថ្ងៃ មិនមានព្រះរាជា គ្រប់គ្រងទេ បច្ចុប្បន្នហៅថា សហេត ម៉ហេត ឬ សាភាវស្ទី នៅក្នុងប្រទេសឥណ្ឌា នៃរដ្ឋយូពី មានចម្ងាយ ២៥៤គ.ម. ពីកុសិនារា, ២៦គ.ម. ពីទីក្រុងបារាំពួរ និង ៣០២គ.ម. ពីពារាណសី ។ បច្ចុប្បន្ន មិនមានអ្វីច្រើនទេ យើងឃើញមានកំផែងនគរសល់បន្តិចបន្តួច ឃ្លាំងទ្រព្យសម្បត្តិរបស់ អនាថបិណ្ឌិកសេដ្ឋី ផ្ទះអង្គុលិមាល ស្ទឹងអចិរវតី នៅខាងជើង ប៉ែកខាងកើត នៃវត្តជេតពន ប្រហែល ៤គ.ម, វត្តបុព្វារាម នៅខាងកើតក្រុងសាវត្ថី នៅខាងមុខវត្តមានរណ្ដៅដែលភិក្ខុទេវទត្ត,នាងចិញ្ចា និងនន្ទមាណព ត្រូវព្រះធរណីស្រូប វត្តរាជិការាមសម្រាប់ភិក្ខុនីនៅជាប់វត្តជេតពន ។ ព្រះអង្គគង់នៅ ១៩ព្រះវស្សា ក្នុងវត្តជេតពន និង ៦ វស្សាក្នុងវត្តបុព្វារាម ក្នុងវត្តជេតពនមាន ព្រះគន្ធកុដិ និង អានន្ទពោធិ៍ គួរឱ្យជ្រះថ្លា, មានព្រះសូត្រជាច្រើន បានសម្ដែងក្នុងនគរសាវត្ថី។ នៅជិតវត្តជេតពន សព្វថ្ងៃ មានវត្តខ្មែរសាវត្ថី និង វត្តថៃ ជាដើម...។



កំផែងនគរសាវត្ថី

# ទីកន្លែងសម្តែងយមកបាដិហារ្យ

នៅជិតក្រុងសាវត្ថី ប៉ែកខាងត្បូង ២៥០០ម៉ែត្រ ពីវត្តជេតពន មាននៅសល់ទីកន្លែងឱ្យចាំបានថា ជាទីកន្លែងសម្តែងយមកបាដិហារ្យ ផ្ចាញ់ពួក និគ្រន្ថ នៅក្នុងថ្ងៃ ១៥កើត ខែអាសាឍ គួរឱ្យជ្រះថ្លាចំពោះ ឫទ្ធិអភិញ្ញារបស់ព្រះលោកនាថ ជាម្ចាស់



ដែលមិនមានសាវ័កណាមួយធ្វើដូចព្រះអង្គបាន កាលនោះទីនេះមានដើមស្វាយមួយដែលដុះឡើងយ៉ាងលឿនរហ័ស ដោយពុទ្ធានុភាព ហើយបានសម្តែងបាដិហារ្យ នៅនឹងដើមស្វាយនោះ មានមនុស្ស ទេវតា ២០កោដិ បានសម្រេចធម៌ (មានសម្តែងពិស្តារក្នុងគម្ពីរធម្មបទ ពុទ្ធវគ្គ)។ បន្ទាប់មកព្រះអង្គស្តេចយាងពីទីនេះ ទៅចាំវស្សាទី៧ នៅនាឋានតាវត្តិង្ស សម្តែងអភិធម្មប្រោសពុទ្ធមាតា និង ពួកទេវតា។ ទិដ្ឋភាពបច្ចុប្បន្ននៅសល់ដូចជា ភ្នំដីមួយ ហើយមានស្នាមឥដ្ឋ រៀបចំត១គ្នាមក "ព្រះសម្មាសម្ពុទ្ធជាបុគ្គលអស្ចារ្យក្នុងលោក"។



សម្តែងអភិធម្មប្រោសពុទ្ធមាតា និងទេវតានៅឋានតាវត្តិង្ស










# ឃ្លាំងផ្ទុកទ្រព្យសម្បត្តិអនាថបិណ្ឌិកសេដ្ឋីក្នុងក្រុងសាវត្ថី

អនាថបិណ្ឌិកសេដ្ឋី ឈ្មោះដើមគឺសុទត្តៈ ជាបុត្រនៃសុមនសេដ្ឋី ក្រុងសាវត្ថីភរិយា ឈ្មោះ បុញ្ញលក្ខណា មានធីតាបីនាក់គឺ នាងមហាសុភទ្ទា ចូឡសុភទ្ទា សុមនា និង កូនប្រុសឈ្មោះកាឡៈ។ ថ្ងៃមួយលោកសេដ្ឋីបានធ្វើជំនួញ ទៅកាន់ក្រុងរាជគ្រឹះ ដោយរទេះ ៥០០ ហើយបានសម្រាកនៅផ្ទះរបស់រាជគហសេដ្ឋីត្រូវជាបងថ្លៃ បន្ទាប់មកបានដឹងថាមានព្រះពុទ្ធត្រាស់ដឹងឡើងក្នុងលោក ក៏មានសេចក្តីជ្រះថ្លា ប្រកបដោយបីតិយ៉ាងខ្លាំង បានធ្វើដំណើរទៅគាល់ព្រះអង្គទាំងយប់ នៅព្រៃសីតវ័ន បានស្តាប់ធម៌សម្រេចជា សោតាបន្នបុគ្គល ហើយយាងព្រះបរមលោកនាថ ទៅកាន់ក្រុងសាវត្ថី។ លោកសេដ្ឋីបានទិញដីពីព្រះអង្គម្ចាស់ជេត១ ឱ្យក្រាលកហាបណៈពេញផ្ទៃដីទំហំ ៨ករីស ស្មើ ១០០០ហត្ថក្នុងតម្លៃ ១៨កោដិ កសាង វិហារ កុដិ សាលា ជាដើម ១៨កោដិ ធ្វើបុណ្យឆ្លង ៩ខែ អស់ ១៨កោដិ សរុប ៥៤កោដិ ឈ្មោះថា វត្តជេតពនព្រោះថា ស្តេចជេតបានជួយកសាងខ្លោងទ្វារ ដាក់ឈ្មោះថា ជេតពន។ (មានពិស្តារក្នុងបិដកលេខ ១០ ទំព័រ២៨៩)។





# ឃ្លាំងផ្ទុកទ្រព្យសម្បត្តិអនាថបិណ្ឌិកសេដ្ឋីក្នុងក្រុងសាវត្ថី



លោកសេដ្ឋីធ្វើទានរហូតអស់ទ្រព្យ ទេវតានៅនឹងផ្ទះលោកសេដ្ឋីក៏ប្រាប់ថា សូមលោកកុំធ្វើទានទៀត លោកសេដ្ឋី បានបណ្តេញទេវតាចេញពីផ្ទះរបស់ខ្លួន ដើម្បីបាននៅបន្តទៀត ទេវតាបានមកសូមទោស ហើយនាំមកនូវ ទ្រព្យសម្បត្តិ ជូនលោកសេដ្ឋី ឱ្យដូចដើមវិញ។ ( មានសម្តែងពិស្តារក្នុងគម្ពីរធម្មបទ បាបវគ្គ )។

ឃ្លាំងទ្រព្យសម្បត្តិលោកសេដ្ឋី នៅក្នុងក្រុងសាវត្ថី ដែលបានបែកបាក់ទៅហើយ សល់ស្នាមឥដ្ឋបន្តិចបន្តួចគួរឱ្យជ្រះថ្លា នឹងលោកសេដ្ឋីណាស់។

## ផ្ទះព្រះអង្គុលិមាលនៅជិតឃ្លាំងរបស់អនាថបិណ្ឌិកសេដ្ឋី

ព្រះអង្គុលិមាល ជាបុត្ររបស់បុរោហិតក្រុងសាវត្ថី

( មានពិស្តារនៅក្នុងបិដកលេខ ២៤ ទំព័រ៤១៨)







# វត្តបុព្វារាមឧបាសិកាវិសាខាកសាង

ឧបាសិកាវិសាខាជាធីតានៃ ធនញ្ជ័យសេដ្ឋី និង នាងសុមនាទេវី នៃភទ្ទិយនគរដែនអង្គៈ ជីតាឈ្មោះ មេណ្ឌកសេដ្ឋី ស្វាមីឈ្មោះ បុណ្ណវឌ្ឍនៈឪពុកក្មេកឈ្មោះ មិគារសេដ្ឋី។ មហាឧបាសិកាវិសាខា បានសម្រេចជាព្រះអរិយបុគ្គលតាំងពីអាយុ ៧ឆ្នាំ មហាឧបាសិកាមានបុត្រ ២០នាក់ ប្រុស១០ ស្រី១០ មាន



ចៅ ៤០០នាក់ អាវរបស់មហាឧបាសិកាឈ្មោះ មហាលតាបសាធន៍ តម្លៃ៩កោដិ ធ្វើអំពីពេជ្រ ៤នាឡិ កែវមុក្តា ១១នាឡិ កែវប្រពាឡ ២២នាឡិ កែវមណី ៣៣នាឡិ។ មហាឧបាសិកា បានកសាងវត្តមួយអស់រយៈពេល ៩ខែ ក្នុងតម្លៃ ២៧កោដិ នៅខាងកើតក្រុងសាវត្ថីឈ្មោះថា វត្តបុព្វារាម មានប្រាសាទធំ មានបន្ទប់១000 បានវេរថ្វាយព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ឧបាសិកាវិសាខា ជាកំពូលលើសឧបាសិកាទាំងឡាយខាងថ្វាយទាន ។ សម័យក្រោយពុទ្ធកាលត្រូវទឹកស្ទឹងអចិរវតី ឡើងគួចពន្លិច អូសយកទៅទាំងអស់ មិនមានសេសសល់អ្វី។ ទីនេះគ្រាន់តែចាំតៗគ្នាមកថា កន្លែងវត្តបុព្វារាម ( មានសម្តែងពិស្តារក្នុងគម្ពីរធម្មបទបុប្ផវគ្គ )។



# កន្លែងព្រះធរណីស្រូបជន ៣នាក់ មុខវត្តជេតពន

១ -នន្ទមាណព រំលោភនាង ឧប្បលវណ្ណាភិក្ខុនី បន្ទាប់មក គាត់ធ្វើដំណើរគេចចេញពីវត្តជេតពនត្រូវព្រះធរណីស្រូប មានស្នាមស្រុតដី ដូចជាត្រពាំងទឹក គួរសង្វេគទោសរបស់កាម ។



១- រណ្ដៅនន្ទមាណព



២ -នាងចិញ្ចាចោទថា ព្រះសម្មាសម្ពុទ្ធប្រព្រឹត្ត អសទ្ធម្មជាមួយនាង ព្រះឥន្ទធ្វើអន្តរាគមន៍ នាងរត់ចេញពី វត្តជេតពន ត្រូវព្រះធរណីស្រូបទីនេះ គួរឱ្យសង្វេគទោសរបស់អវិជ្ជា។



២-រណ្ដៅនាងចិញ្ចា

៣ -ភិក្ខុទេវទត្ត ធ្វើលោហិតុប្បាទបាទផង បំបែកសង្ឃផង ត្រូវព្រះធរណីស្រូប នៅខាងមុខវត្តជេតពន គួរសង្វេគទោសរបស់ មានះ ទិដ្ឋិ តណ្ហា។



៣-រណ្ដៅភិក្ខុទេវទត្ត

***<u>ភ្លើងនរកក្ដៅណាស់មិនគួរធ្វើអំពើបាបទេ!</u>***

# វត្តជេតពនជិតក្រុងសាវត្ថី







វត្តជេតពនបាន
កសាងដោយលោក
អនាថបិណ្ឌិកសេដ្ឋី ក្នុង
ផ្ទៃដី ៨ករីស ស្មើ១០០០
ហត្ថ អស់ប្រាក់ ៥៤កោដិ ។ ពុទ្ធ
បរិស័ទខ្មែរយើងទាំងអស់គ្នាបាន
ចូលទៅទស្សនា វត្តជេតពន នឹក
ដល់សម័យពុទ្ធកាលព្រះអង្គបាន
គង់នៅក្នុងវត្តជេតពនច្រើនជាង
ទីដទៃដល់ទៅ ១៩វស្សា ក្នុងវត្ត
នេះ ដើម្បីអនុគ្រោះដល់លោក
សេដ្ឋី និង មហាជនជាច្រើននៅ
ក្នុងក្រុងនេះ ។


ខឿនព្រះវិហារជេតពន


ខឿនកុដិព្រះសីវលី







# មូលគន្ធកុដិ ក្នុងវត្តជេតពន

ពាក្យថាគន្ធកុដិប្រែថា ជាកុដិក្រអូប គឺក្រអូបដោយផ្កាឈើដែលទេវតា មនុស្សបូជា ហើយនឹងក្រអូបដោយធមិ ដែលព្រះអង្គសម្តែង ។ ព្រះអង្គទ្រង់គង់ក្នុងព្រះគន្ធ-កុដិ ដែលជាទីកន្លែងនៃព្រះពុទ្ធគ្រប់ព្រះអង្គធ្លាប់គង់នៅ ហៅថា អចលចេតិយដ្ឋាន ។ អចលចេតិយ នៃព្រះពុទ្ធគ្រប់ព្រះអង្គធ្លាប់អាស្រ័យនៅមាន ៤កន្លែង គឺ :



មូលគន្ធកុដិព្រះសម្មាសម្ពុទ្ធ





មូលគន្ធកុដិ ក្នុងវត្តជេតពន ជាកន្លែងព្រះអង្គសម្តែងមង្គលសូត្រ បរាភវសូត្រ ជាដើមមានទេវតា បានសម្រេចធមិរាប់ប្រមាណមិនបាននៅក្នុងវត្តជេតពននេះ ។

១ -កន្លែងព្រះសម្មាសម្ពុទ្ធត្រាស់ដឹង

២ -កន្លែងសម្តែងធម្មចក្កប្បវត្តនសូត្រ

៣ -ខ្លោងទ្វារគនរសង្កស្សៈ ជាកន្លែងព្រះអង្គចុះពីឋានទេវលោក

៤ -កន្លែងតម្កល់គ្រែក្នុងមូលគន្ធកុដិនៃវត្តជេតពន



កុដិព្រះសារីបុត្តក្នុងវត្តជេតពន



ទិដ្ឋភាពក្នុងវត្តជេតពន



# អានន្ទពោធិព្រឹក្ស

## ប្រវត្តិសង្ខេបនៃអានន្ទពោធិព្រឹក្សក្នុងវត្តជេតពន




ព្រះអានន្ទ បានគិតថាពេលបរិស័ទទាំងឡាយ មកវត្តជេតពននេះ ដើម្បីគោរពបូជាពេលខ្លះព្រះអង្គមិនបានគង់នៅ មិនមានបុគ្គលណាមួយជំនួសព្រះអង្គបាន ទើបព្រះអានន្ទ ទូលសួរព្រះអង្គថាខ្ញុំព្រះអង្គអាចធ្វើព្រះចេតិយ ទុកសម្រាប់បរិស័ទទាំងឡាយគោរពបូជា បានទេ ? ព្រះអង្គត្រាស់ថា ធាតុចេតិយមិនអាចធ្វើបានទេ តែពោធិព្រឹក្សអាចជំនួសព្រះអង្គបាន។



ព្រះអានន្ទ សូមឱ្យព្រះ មោគ្គល្លានទៅយកគ្រាប់ពោធិ៍ពីពុទ្ធគយា អនាថបិណ្ឌិកសេដ្ឋី បានដាំភ្លាមធំភ្លែត នៅនឹងផ្លូវចូលវត្តជេតពន។ ព្រះរាជាស្រោចសុគន្ធវារី ព្រះអានន្ទអ្នកថែរក្សាទើបឈ្មោះថា អានន្ទពោធិ៍ ។ ព្រះសាស្ដា ចូលនិរោធសមាបត្តិ ៧ថ្ងៃក្រោមដើមពោធិ៍ ហើយដើមនេះមានអាយុរហូតមកដល់សព្វថ្ងៃ។



# ស្ទឹងអចិរវតី

នៅក្បែរក្រុងសាវត្ថី មានស្ទឹងមួយយ៉ាងធំឈ្មោះថាអចិរវតី អ្នកនគរសាវត្ថីអាស្រ័យដោយទឹកស្ទឹងនេះ ហើយមានប្រវត្តិថា នាង-បដាចារ បានឆ្លងទឹកស្ទឹងនេះ កូនទាំង២នាក់ មួយត្រូវ ស្លាប់ដោយទឹកគួច មួយទៀតត្រូវខ្លែងឆាប នាងមានសេចក្ដីសោកជាខ្លាំងហើយ បន្ទាប់មកបានដឹងថាមាតាបិតា និង បងប្រុសក៏ស្លាប់ដែរ ដោយគ្រោះមហន្តរាយនៃព្យុះ-សង្ឃរា និង អគ្គីភ័យ នាងក៏សន្លប់បាត់ស្មារតី ប៉ុន្តែដោយបុណ្យបានស្ដាប់ធម៌ព្រះសាស្ដា -



ហើយបានបួសជាភិក្ខុនីសម្រេចជាព្រះអរហន្តី ។ ក្រៅពីស្ទឹងនេះក៏មានប្រវត្តិផងដែរថា វិឌូឌភៈ បន្ទាប់ពីបានលើកទ័ពសម្លាប់ពួកសក្យវង្ស នៅពេលត្រឡប់មកវិញ បានសម្រាកលើដីខ្សាច់ក្នុងស្ទឹងអចិរវតីនេះនារដូវប្រាំង ក៏ប៉ុន្តែ ដោយកម្លាំងកម្មស្រាប់តែមានទឹកជំនន់យ៉ាងធំ គួចពន្លិចស្លាប់ទាំងអស់ ។



ស្ទឹងអចិរវតីនារដូវប្រាំង



ស្ទឹងអចិរវតីនារដូវវស្សា
ថតពេលមេឃចុះអ័ព្ទ

ជីវិតគឺប្រែប្រួល

ជីវិតគឺជាទុក្ខ

ជីវិតគឺធម្ម (មិនមែនជារបស់ខ្លួន)

# វត្តឃោសិតារាម ក្រុងកោសម្ពី







សសរស្តម្ភនៅវត្តឃោសិតារាម

ក្រុងកោសម្ពី គ្រប់គ្រងដោយព្រះបាទ ឧទេន ព្រះអង្គមានអគ្គមហេសីគឺ នាងសមាវតី នាងមាគន្ទិយា និងនាងវាសុលទត្តា



(មានសម្តែងពិស្តារក្នុងគម្ពីរធម្មបទ អប្ប-មាទវគ្គ) ។ សព្វថ្ងៃទីនេះ នៅក្នុងរដ្ឋយូពី ភាគខាងជើង នៅជិតទីក្រុង អាឡាហាបាត និង ជិតស្ទឹង យមុនា ដែលជាខ្សែស្ទឹងហូរមកដល់ក្រុង-ពារាណសី មានចម្ងាយ ៣០យោជន៍។ ឃោសិកសេដ្ឋី ជាព្រះអរិយបុគ្គល បានកសាងវត្តមួយឈ្មោះថា ឃោសិតារាម



ក្បែរក្រុងកោសម្ពី ព្រះលោកនាថ បានគង់ចាំវស្សាទី៩។ សព្វថ្ងៃមានសសរស្តម្ភព្រះ-បាទធម្មាសោក បានកសាងទុកបញ្ជាក់ថាទីនេះឃោសិតារាម ។

# វត្តខ្មែរកុរុរដ្ឋខេមរារាម ញូវដែលី

វត្តនេះ ស្ថិតនៅក្នុងទីក្រុងញូវដែលី សម័យពុទ្ធកាលហៅថា ដែនកុរុ ។ ចាប់ផ្តើមកសាងវត្តនេះ









ដោយ ព្រះមហាឥសីប្រសឹតមាន កុដិ វិហារ និង អាគារសម្រាប់ពុទ្ធបរិស័ទស្នាក់នៅ ។ ពុទ្ធបរិស័ទដែលអញ្ជើញមកដែនដីពុទ្ធភូមិ តែងតែស្នាក់នៅក្នុងវត្តនេះ បន្ទាប់ពីចុះពីយន្តហោះ ។









# តំបន់អក្ខរាមានវិហារឥស្លាមយ៉ាងធំឈ្មោះ ប្រាសាទតាចមាហាល់















តាមដំណើរផ្លូវពីសង្កស្ស: ទៅញូវដែលី យើងបានចូលទស្សនាតំបន់អក្ខរានេះ មានវិហារ-ឥស្លាមយ៉ាងធំ ដែលពួកឥស្លាមតែងគោរពបូជាទីនេះនៅក្នុងរដ្ឋយូពីជិតស្ទឹងយមុនា ២០៣គ.ម. ពីញូវដែលី កសាងក្នុងគ.ស.១៦៣២ ដល់១៦៥៣ ដោយស្តេចសាចាហាន់ ជាអនុស្សាវរីយ៍ នៃផ្នូរអគ្គមហេសីឈ្មោះ មាតាសមាហាល់ ។ ចូលជាបេតិកភណ្ឌពិភពលោកក្នុង គ.ស. ១៩៨៣ ។ អ្នកស្រុកចិញ្ចឹមសត្វអូដ្ឋ ដើម្បីអូសរទេះនាំភ្ញៀវទេសចរណ៍ទៅទស្សនា ។

# សារមន្ទីរជាតិ

ក្នុងទីក្រុងញូវដែលី នៃប្រទេសឥណ្ឌា មានសារមន្ទី ដ៏ធំមួយ ដែលតម្កល់បដិមាពីបុរាណជាច្រើន ដូចជា រូបសត្វ រូបមនុស្ស រូបទេវៈ ក្បាច់ចម្លាក់ ជាពិសេស ព្រះពុទ្ធបដិមា គួរឱ្យទស្សនា។




























វិមានឯករាជ្យឥណ្ឌា (ញូវដែលី)

# ស្ថានទីសម្តែងសតិប្បដ្ឋានសូត្រ

ក្នុងសុត្តន្តបិដក ទីឃនិកាយភាគ ១៧ មានសម្តែង សតិប្បដ្ឋានសូត្រ ។ ព្រះអង្គបានសម្តែងសតិប្បដ្ឋានសូត្រ ក្នុងដែនកុរុ ក្នុងកម្មាសធម្មនិគម សព្វថ្ងៃហៅថា ញូវដែលី ជាទីក្រុងធំមួយនៃប្រទេសឥណ្ឌា ។ ទិដ្ឋភាពបច្ចុប្បន្នមាន ស្តូបតូចមួយ ឋិតនៅលើកូនភ្នំដែលបញ្ជាក់ថា ព្រះអង្គ សម្តែងសតិប្បដ្ឋានសូត្រក្នុងទីនេះឯង ( ផ្លូវមូលតែមួយ ទៅកាន់ព្រះនិព្វានគឺ សតិប្បដ្ឋានបដិបត្តិ ) ។







ធម្មយាត្រាលើកទី៤ ដែលដឹកនាំដោយលោកគ្រូធម្មាចារ្យ តែង ខិម្ហួត ព.ស.២៥៥៣





# ឧទ្យាន មិគាចីរៈ











ក្បែរក្រុង ញូវដែលី មានឧទ្យានមួយគួរជាទីរីករាយ ជាកន្លែងព្រះសង្ឃសូធ្យជយន្តោ ជូនពរដល់ប្រធានាធិបតីឥណ្ឌា សម័យមុន ឈ្មោះ នេរុ ទើបហៅថាឧទ្យានជយន្តោ។ សម័យពុទ្ធកាលហៅថា មិគាចីរៈឧទ្យាន ក្នុងស្រុកថុល្លកោដ្ឋិតៈ នៃដែនកុរុ។ ព្រះរដ្ឋបាល បានសម្តែងធម្មទ្ទេស ៤យ៉ាង ដល់ព្រះបាទកោរព្យរាជ។

(គួរជ្រះថ្លា នឹងព្រះរដ្ឋបាល កំពូលលើសភិក្ខុទាំងឡាយ ផ្នែកខាងផ្នួសដោយសទ្ធា) " បិដកលេខ ២៤ ទំព័រ ២៦៨ "។

# ខ្លោងទ្វារនគរសង្កស្ស: ព្រះអង្គចុះពីទេវលោក



នគរសង្កស្ស: មានចម្ងាយ ៦១៦ គ.ម. ពីញូវដែលី មហាជនក្នុងក្រុងសាវត្ថី បានដឹងដំណឹងតាមព្រះមហាមោគ្គល្លានថាព្រះអង្គនឹងយាងចុះពីទេវលោកត្រង់ខ្លោងទ្វារនគរសង្កស្ស: ទើបមហាជនទាំងនោះ ធ្វើដំណើរចេញពីក្រុងសាវត្ថី ទៅសង្កស្ស:ប្រវែង ៣០យោជន៏ ដើម្បីចាំទទួលព្រះអង្គ។ សសរស្តម្ភដែលបាក់ពាក់កណ្តាលសល់តែខាងចុង មានរូបដំរីនៅពីលើបានដាក់







បញ្ឈរក្រោមដើមពោធិព្រឹក្ស បញ្ជាក់ថា ទីនេះជាខ្លោងទ្វារ នៃនគរសង្កស្ស: កន្លែងព្រះអង្គចុះពី



ខឿនចេតិយចាស់



បន្ទាប់ពីព្រះអង្គសម្តែងព្រះ **អភិធម្ម** ប្រោសពុទ្ធមាតា និងពួកទេវតាៗបានសម្រេចធម៌ ៨០កោដិ ថ្ងៃចេញវស្សា ព្រះអង្គស្តេចយាង ចុះមកពីឋានតាវត្តិង្ស តាមជណ្តើរកែវ ព្រះឥន្ទកាន់បាត្រចុះតាមជណ្តើរមាស នៅខាងស្តាំ



មហាព្រហ្មកាន់ស្វេតឆត្រ ចុះតាមជណ្តើរប្រាក់ខាងឆ្វេង។ ព្រះសម្មាសម្ពុទ្ធ សម្តែងឫទ្ធិ បាដិហារ្យ បើកលោក ឱ្យមនុស្សបានឃើញនរកនិងទេវតា។ ទីនេះឈ្មោះថា អចលចេតិយស្ថានកន្លែងព្រះពុទ្ធគ្រប់ព្រះអង្គចុះពីឋានតាវត្តិង្ស ។ កាលនោះបរិស័ទទាំងឡាយបានស្តាប់ធម៌ បានសម្រេចធម្មាភិសម័យ(មគ្គផល)៣០ កោដិ មានពិស្តារក្នុងអដ្ឋកថាធម្មបទពុទ្ធវគ្គ។





# គេហដ្ឋានរបស់នាយចុន្ទ (កន្លែងព្រះអង្គសោយចង្ហាន់ចុងក្រោយ)



ចម្ងាយពីផ្ទះរបស់នាយចុន្ទ ទៅកុសិនារា គឺ ១៧ គីឡូម៉ែត្រ

ក្នុងពេលព្រឹក ១៥កើត ខែពិសាខ ឆ្នាំម្សាញ់ នាយចុន្ទកម្មារបុត្រ បាននិមន្តព្រះសម្មាសម្ពុទ្ធ និងភិក្ខុសង្ឃ ទទួលភត្តក្នុងផ្ទះរបស់ខ្លួន បានរៀប



ចំនំឈ្មោះសូករមទ្ទវៈ(នំធ្វើអំពីសាច់ជ្រូកដ៏ប្រសើរ) ពួកទេវតាជាច្រើនបាននាំយកឱជារសទិព្វ មកបញ្ចូលក្នុងសូករមទ្ទវៈ ដើម្បីថ្វាយព្រះពុទ្ធជាម្ចាស់ ព្រះអង្គមិនអនុញ្ញាតអោយនាយចុន្ទប្រគេនសូករមទ្ទវដល់ភិក្ខុសង្ឃទេ ព្រោះមានរសជាតិឆ្ងាញ់ពេកមនុស្ស និង ទេវតាមិនអាចបរិភោគបាន បើបរិភោគនឹងត្រូវស្លាប់ (វៀរលែងតែព្រះសម្មាសម្ពុទ្ធ) ព្រះអង្គបានទទួលចង្ហាន់របស់នាយចុន្ទជាលើកចុងក្រោយ ក្នុងជីវិតរបស់ព្រះអង្គ។ ទិដ្ឋភាពបច្ចុប្បន្ន ឃើញមានស្នាមខឿនឥដ្ឋខ្លះៗ ប៉ុណ្ណោះ (គួរជ្រះថ្លាចំពោះនាយចុន្ទ ដែលបានថ្វាយចង្ហាន់ចំ-ពោះព្រះសម្មាសម្ពុទ្ធ ក្នុងពេលចុងក្រោយ)។





# នគរកុសិនារា

សម័យព្រះរាជាព្រះនាម **មហាសុទស្សនៈ** ជាព្រះ**បរមពោធិសត្វ** នគរនេះមានឈ្មោះថា**កុសាវតី** (បិដកលេខ១៧មហាសុទស្សនៈសូត្រ) ជានគរធំសម័យពុទ្ធកាលមានឈ្មោះថា**កុសិនារា** ជានគរតូចគ្រប់គ្រងដោយស្តេច **មល្លៈ** បច្ចុប្បន្នហៅក្លាយមកជា **កុសិនាគា** នៅប្រទេសឥណ្ឌាក្នុងរដ្ឋ**យូពី** ជាប់ព្រំប្រទល់នឹងប្រទេស នេប៉ាល់ មានចម្ងាយ ១៧៣ គ.ម.ពីលុម្ពិនី,២៦៦គ.ម.ពីសារនាថ, ២៩៤ គ.ម.ពីសាវត្ថី និង ៤៤គ.ម. ពីប្រលានយន្តហោះ គូរ៉ាកពួរ ។ មានវត្តជាច្រើន ដូចជា: វត្តខ្មែរ វត្តថៃ វត្តស្រីលង្កា វត្តជប៉ុន វត្តចិន វត្តភូមា វត្តកូរ៉េជាដើម...។ កន្លែងព្រះអង្គបរិនិព្វាន គេកសាងនូវព្រះវិហារក្នុងឧទ្យានពីបុរាណឈ្មោះថា **និព្វានវិហារ** ដែលមានព្រះពុទ្ធបដិមាបរិនិព្វានបែរព្រះភ័ក្រ្តទៅ - ទិសខាងលិច ដែលមានប្រវែង ៦ម៉ែត្រ ១តឹក កសាងតាំងពីសម័យព្រះបាទ **ធម្មាសោក** សព្វថ្ងៃមានពុទ្ធបរិស័ទមកពីបណ្តាប្រទេសទាំងឡាយ បូជាគ្រឿងសក្ការៈជាច្រើន ។ ហើយពេលបានឃើញព្រះពុទ្ធបដិមា ទ្រង់ចូលបរិនិព្វាន អ្នកខ្លះមានសេចក្តីសង្វេគ និង សេចក្តីសោក ខ្សឹកខ្សួលអួលអាក់នឹកអាល័យសែនស្រណោះ អស់ពីចិត្តគិតដល់ព្រះលោកនាថ ទ្រង់បានបរិនិព្វានទៅហើយ ។





# នគរកុសិនារា ស្ថានទីបរិនិព្វាន



និព្វានវិហារ

ក្នុងវេលាថ្ងៃល្ងាច ១៥ កើត ខែពិសាខ ព្រះអង្គឱ្យព្រះអានន្ទ រៀបចំគ្រែ មានក្បាលដំណេកទៅទិសខាងជើង ក្នុងចន្លោះ ដើមសាលព្រឹក្សទាំងគូ ក្នុងឧទ្យានរបស់ពួកមល្លក្សត្រ ។ ព្រះដ៏មានព្រះភាគ មានសតិសម្បជញ្ញៈ ទ្រង់សម្រេចសីហសីយា ផ្ទៀងទៅខាងស្ដាំ ទ្រង់យកព្រះបាទឆ្វេងតម្រួតលើព្រះបាទស្ដាំ សម័យនោះឯង សាលព្រឹក្សទាំងគូ មានផ្ការីកស្គុសស្គាយតាំងពីគល់ដល់ចុងមែក ពួកទេវតាទាំងឡាយ បូជាដោយគ្រឿងក្រអូប និង តូរ្យតន្ត្រីដែលជាទិព្វបូជាព្រះអង្គ មនុស្ស ទេវតាបានដឹងថា ព្រះអង្គនឹងបរិនិព្វានក៏មានសេចក្ដីសោកខ្សឹកខ្សួលជាខ្លាំង ។ កាលនោះព្រះអានន្ទ បានសួរសំនួរជាច្រើនចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានព្រះតម្រាស់យ៉ាងច្រើនចំពោះព្រះអានន្ទ និង ភិក្ខុទាំងឡាយ ( សេចក្ដីពិស្ដារក្នុងសុត្តន្តបិដកទីឃនិកាយភាគ ១៦ មហាបរិនិព្វានសូត្រ ) ។ ព្រះពុទ្ធតម្រាស់ចុងក្រោយថា : *អថខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ។ អយំ តថាគតស្ស បច្ឆិមា វាចា ។* គ្រានោះព្រះមានព្រះភាគទ្រង់ត្រាស់ នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយណ្ហើយចុះឥឡូវនេះ តថាគត ប្រាប់អ្នកទាំងឡាយឱ្យបានដឹង សង្ខារទាំងឡាយ មានសេចក្ដីសាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងពួងឱ្យ-







# នគរកុសិនារា ស្ថានទីបរិនិព្វាន



ព្រះពុទ្ធបដិមាក្នុងនិព្វានវិហារគួរឱ្យសង្វេគ

សម្រេចដោយសេចក្ដីមិនប្រមាទចុះ ។ នេះជាបច្ឆិមវាចារបស់ព្រះតថាគត ។ បន្ទាប់មកព្រះអង្គចូលឈានសមាបត្តិ មានបឋមឈានជាដើម ទាំងអស់គឺ ២៤ សែនកោដិសមាបត្តិ ហើយទ្រង់បរិនិព្វាន ដោយមិនមានសេចក្ដីអាល័យក្នុងលោកនេះ ។ ព្រះអង្គបរិនិព្វានក្នុងព្រះជន្ម ៨០ នៅថ្ងៃអង្គារ យាមអង្គារ ក្នុងបច្ចូសសម័យ ថ្ងៃពេញ-បូណ៌មីខែពិសាខ ឆ្នាំម្សាញ់ ។ កាលព្រះដ៏មានព្រះភាគបរិនិព្វានហើយ ការកក្រើកផែនដីដ៏ធំគួរឱ្យព្រឺរោម ក៏កើតមានទាំងស្គរនៃទេវតា ក៏លាន់ឮគគ្រឹកគគ្រេង ព្រមនឹងការបរិនិព្វាន ។ មនុស្ស និងទេវតាមានសេចក្ដីសោកយ៉ាងពន់ពេក (វៀរលែងតែព្រះអរហន្ត) ។













ឧបាសិកា អ៊ឹម ថុល (ស្ទូត)

# មកុដពន្ធនចេតិយ (កន្លែងបូជាព្រះសរីរៈ)

ព្រះសារីរិកធាតុ



នមស្ការប្រទក្សិណជុំវិញមកុដពន្ធនចេតិយ

បន្ទាប់ពីព្រះអង្គបរិនិព្វាន ៧ថ្ងៃ ទើបពួកមល្លក្សត្របានរៀបចំពិធីបូជាព្រះសរីរៈត្រង់មកុដពន្ធនចេតិយ ទៅទិសខាងកើត នៃឧ-ទ្យាន។ ពិធីនេះរៀបចំ ដូចជារៀបចំបូជាស្តេចចក្រពត្តិ បន្ទាប់អំពី ព្រះមហាកស្សបបានមកដល់ថ្វាយបង្គំហើយ។ ជើងថ្ករក្តារមឈូសមាស ព្រះដ៏មានព្រះភាគ ក៏ឆេះឯងនៅសល់តែព្រះបរមសារីរិកធាតុ ដែលពណ៌ដូចផ្កាម្លិះក្រពុំ ខ្លះដូចកែវមុក្តាដ៏ស្អាតខ្លះដូចកំទេចមាស។



# មកុដពន្ធនចេតិយ (កន្លែងបូជាព្រះសរីរៈ)



ទោណព្រាហ្ម បានចែកព្រះធាតុទៅ ៨នគរ ស្មើៗ គ្នា ។ ទិដ្ឋភាពបច្ចុប្បន្នមានរៀបចំដូច



ជា ភ្នំឥដ្ឋ ដ៏ធំ រៀប ចំឧទ្យាន និង ផ្កា ឈើយ៉ាងស្រស់ស្អាត គួរជ្រះថ្លាក្រៃពេក (សេចក្តី ពិស្តារបិដក ភាគ ១៦ ) ។

ទីនេះ នៅខាងកើតកន្លែងព្រះអង្គបរិនិព្វាន ប្រហែល ជាង ១ពាន់ម៉ែត្រ







# អ្នកឧបត្ថម្ភជំសៀវភៅនេះ



USA ឧ.ស. លីម ម៉េងដាច និង ឧ.សិ. អ៊ុង គីមគី
(២០០០ ដុល្លារ)



ភ្នំពេញ ឧ.ស. ជា សុខុម និង ឧ.សិ. អ៊ុន ពូន
(២០០០ ដុល្លារ)



USA ឧ.សិ. ឆាន់ ហៃតឹង
(១៥០០ ដុល្លារ)



USA ឧ.សិ. ស៊ន ឡៀង
(៥០០ ដុល្លារ)



USA ឧ.សិ.ឆាន់ ឆាន់ជួង និង ស្វាមី
(៥០០ ដុល្លារ )



USA ឧ.សិ.តាំង ចាន់ធូ
(៥០០.ដុល្លារ)





# រូបពុទ្ធបរិស័ទចូលរួមឧបត្ថម្ភ
# បោះពុម្ព សៀវភៅ ដែនដីពុទ្ធភូមិ
# ជា ធម្មទាន









ពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិក









ក្រុមកល្យាណមិត្ត លោក លីម ហេង
និង អ្នកស្រី តៃ ហុង

ពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិក

ឧបាសក តាំង ប៉េងជីង
ឧបាសិកា លីម អ៊ីហ៊ាម











ឧបាសិកា គ្រុយ ឡាំងជន់
លោក លីម ម៉េងលាង អ្នកស្រី អន ម៉ុំ

ឧបាសក ឆា សុង
ឧបាសិកា ទៅ ចាន់ខេង









លោក ហេង គីមថា
អ្នកស្រី ជាន មួយឡេង

លោក ហ៊ី ព្រូ
អ្នកស្រី ទូច ស្រីស

ឧបាសិកា ម៉ៅ គីមសីន

ឧបាសិកា ពៅ

# មាតិកា


១-ឥណ្ឌា-នេប៉ាល់ សង្ខេប..... ១
២-ឧទ្យានលុម្ពិនី..... ២
៣-វត្តខ្មែរលុម្ពិនី..... ៦
៤-នគរកបិលពស្តុ..... ៧
៥ ព្រះស្តូបពុទ្ធមាតា ពុទ្ធបិតា..... ៨
៦-កន្លែងព្រះពុទ្ធកក្កុសន្ធោប្រសូត..... ១០
៧-កន្លែងព្រះពុទ្ធកោនាគមនោប្រសូត..... ១១
៨-វត្តនិគ្រោធារាម..... ១២
៩-ស្ទឹងរោហិណី..... ១៣
១០-ព្រះចេតិយរាមគ្រាម..... ១៤
១១-ព្រះចេតិយនគរកបិលពស្តុថ្មី..... ១៥
១២-ភ្នំបាឡាផ្លាវើ..... ១៦
១៣-ភ្នំទុក្ខសិរិ..... ១៧
១៤-ឧបាសិកា សុជាតា..... ១៩
១៥-ស្ទឹងនេរញ្ជរា..... ២០
១៦-ពុទ្ធគយា..... ២១
១៧-ព្រះអង្គផ្ចាញ់មារ..... ២២
១៨-ប្រវត្តិសង្ខេបមហាពោធិ៍ទាំងបួន..... ២៥
១៩- ភ្នំគយាសីសៈ..... ២៦
២០-សត្តមហាឋាន..... ២៧
២១-ព្រះពុទ្ធរូបអង្គធំ..... ៣០
២២-វត្តខ្មែរពុទ្ធគយា..... ៣២
២៣-ស្ទឹងគយាសីសៈ..... ៣៣
២៤-ទន្លេគង្គា..... ៣៤
២៥-ព្រះចៅគណ្ឌីស្តូប..... ៣៥
២៦-ធម្មេក្ខស្តូប..... ៣៦
២៧-វត្តស្រីលង្កាជិតធម្មេក្ខស្តូប..... ៣៨
២៨-ព្រះគន្ធកុដិថ្មី..... ៣៩
២៩-ក្រុងរាជគ្រឹះ..... ៤០
៣០-ព្រះគន្ធកុដិលើភ្នំគិជ្ឈកូដ..... ៤៤
៣១-ស្ទឹងតបោទា..... ៤៥
៣២-បិប្ផលិគុហា..... ៤៦
៣៣-ភ្នំវេភារៈ..... ៤៧
៣៤-វត្តជីវកម្ពវ័ន..... ៤៨
៣៥-វាំងចាស់នៃនគររាជគ្រឹះ..... ៤៩
៣៦-ឃ្លាំងព្រទ្យព្រះបាទពិម្ពិសារ..... ៥០
៣៧-គុកឃុំឃាំងព្រះបាទពិម្ពិសារ..... ៥១
៣៨-វត្តវេឡុវ័ន..... ៥២
៣៩-ព្រះចេតិយធាតុនិធាន..... ៥៥
៤០-ភ្នំកុក្កុដសមបាត..... ៥៦
៤១-សាកលវិទ្យាល័យនាលន្ទា..... ៥៨
៤២-កន្លែងព្រះសារីបុត្តប្រសូត និងបរិនិព្វាន..... ៦០
៤៣-វត្តអសោការាម..... ៦១
៤៤-ក្រុងវេសាលី..... ៦៣
៤៥-អម្ពបាលិវ័ន..... ៦៥
៤៦-កូដាគារសាលាមហាវ័ន..... ៦៨
៤៧-ដាក់អាយុសង្ខា..... ៧១
៤៨-នគរសាវត្ថី..... ៧៣
៤៩-យមកបាដិហារ្យ..... ៧៤
៥០-ឃ្លាំងទ្រព្យអនាថបិណ្ឌិកសេដ្ឋី..... ៧៥
៥១-វត្តបុព្វារាម..... ៧៧
៥២-រណ្តៅព្រះធរណីស្រូបមុខវត្តជេតពន..... ៧៨
៥៣-វត្តជេតពន..... ៧៩
៥៤-មូលគន្ធកុដិ..... ៨០
៥៥-អានន្ទពោធិ៍..... ៨១
៥៦-ស្ទឹងអចិរវតី..... ៨២
៥៧-វត្តឃោសិតារាម..... ៨៣
៥៨-វត្តខ្មែរកុរុរដ្ឋខេមរារាម..... ៨៤
៥៩-តំបន់អក្ខរា..... ៨៥
៦០-សារមន្ទីរឥណ្ឌា..... ៨៦
៦១-សតិប្បដ្ឋានសូត្រ..... ៨៧
៦២-ឧទ្យានមិគាចីរៈ..... ៨៨
៦៣-សង្កស្សៈ..... ៨៩
៦៤-ផ្ទះនាយចុន្ទ..... ៩១
៦៥-នគរកុសិនារា..... ៩២
៦៦-មកុដពន្ធនចេតិយ..... ៩៥

# នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅជាធម្មទាន

១ -ឧ.ស ជា សុខុម និង ឧ.សិ អ៊ុនពូន ព្រមទាំងបុត្រ.............២.០០០ $ ភ.ព

២ -ឧ.ស លឹម ម៉េងដាវ និង ឧ.សិ អ៊ុងគីមគីព្រមទាំងបុត្រ.....២.០០០ $ ស.រ

៣ -ឧ.សិ ឆាន់ ហៃកឹង ព្រមទាំងបុត្រ...............................១.៥០០ $ ស.រ

៤ -លោកគ្រូ បណ្ឌិត អឿ សៅ..........................................៥០០ $ ស.រ

៥ -ឧ.សិ ស៊ិន លេង ព្រមទាំងបុត្រ...................................៥០០ $ ស.រ

៦ -ឧ.ស វង្ស ម៉ៅ និង ឧ.សិ ឆាន់ កាន់ជួង..........................៥០០ $ ស.រ

៧ -ឧ.សិ តាំង ចន្ទូ និង កូនស្រី ហ្សេន លី............................៥០០ $ ស.រ

៨ -ឧ.សិ ភន ស៊ាងហៃ និង ឧ.សិ កុល សុម៉ាលី.....................៤០០ $ ស.រ

៩ -លោក ស៊ុន ពៅ និង លឹម មួយ ព្រមទាំងបុត្រ និងចៅ.........៣០០ $

១០ -ឧ.ស ជីវ ស៊ូ គុយ ឧ.សិ អៀ គុយហួង ព្រមទាំបុត្រ.............២០០ $ ភ.ព

១១-ឧ.ស លី សុងហួរ និង ឧ.សិ ស៊ូ អេង ព្រមទាំងបុត្រ...........២០០ $ ភ.ព

១២-ឧ.សិ ទា សុង និង ឧ.សិ ង៉ោ ចាន់ខេង ព្រមទាងកូនចៅ.........២០០ $ ភ.ព

១៣-ឧ.សិ កាំង ប៉េងជីវ ឧ.សិ លឹម អ៊ីហ៊ាម.............................២០០ $ ភ.ព

១៤ -លោក ឡាយ វេងឈុន និង ម៉ៅ សុភាព ព្រមទាំងបុត្រ....... ២០០ $ ភ.ព

១៥ -ឧ.សិ មិ យន ម្តាយលោកគ្រូ កែវ វិមុត្ត.............................២០០ $

១៦-ព្រះភិក្ខុង៉ែត យន ឧ.សិ ញ៉ែម យ៉ម និង កូន សុទ្ធា...............២០០ $

១៧-អ.ស្រី ចានីរ ព្រមទាំងបុត្រ............................................២០០ $ ស.រ

១៨-ឧ.សិ លី ស៊ូហ្គេច ព្រមទាំងកូនចៅ.................................២០០ $

១៩ -ឧ.ស ប៊ុន ហួរ និង ឧបាសិកា ហេង ណៃគីម.......................១០០ $ ភ.ព

២០ -លោក ហេង គីមថា អ្នកស្រី ជាន មួយឡេង.....................១០០ $ ភ.ព

២១-ឧ.សិ គ្រុយ ឡាំងជន់,ម៉េង លាង និង អ្នកស្រី អន មុំ...........១០០ $ ភ.ព

២២-លោក ហ៊ី ព្រូ លោកស្រី ទូច ស្រីស ព្រមទាំងបុត្រ..............១០០ $ ភ.ព

២៣-លោក ឡាយ ហួរ និង លី មុយហ៊ួង ព្រមទាំងបុត្រ.............១០០ $ ភ.ព

២៤ -លោក លឹម ហេងស្រេង និង ឆៃ ហុង ព្រមទាំងបុត្រ..........១០០ $ ភ.ព

២៥ -លោក យូ ហៀបសាយ អ.ស្រី លឹម អៃមុំ និងបុត្រ...........១០០ $

២៦ -លោក ទី គីមសាន អ.ស្រី លឹម គីមផ្លុង និងបុត្រ............១០០ $

២៧-អ្នកស្រី លឹម គីមឡាយ ព្រមទាំងកូនស្រី.........................១០០ $

២៨-អ្នកស្រី លឹម គីមប៊ួយ....................................................១០០ $

២៩ -ឧ.សិ អ៊ុក ទូរ៉េត ព្រមទាំងបុត្រ........................................១០០ $

៣០-ព្រះភិក្ខុ ប៉ាត សុផល................................................... ១០០ $ ស.រ

៣១-ឧ.សិ ម៉ម ចាន់ហម...................................................... ១០០ $

៣២-ឧ.សិ ឆេង ឃុនណារី ព្រមទាំងបុត្រ.................................១០០ $

៣៣-ឧ.ស ឆេង គីមថៃ និង ភរិយា.........................................១០០ $ ស៊ីស

៣៤-ឧ.សិតាំង ហៀង............................................................១០០ $ ស.រ

៣៥- ម៉ា រុងថូ..................................................................១០០ $ ស.រ

៣៦-ឧ.សិ លីប៊ូលីន ស៊ីនប៊ូ.................................................១០០ $ ស.រ

៣៧-ឧ.សិ ឡៅ គីមថៃ ព្រមទាំងបុត្រ.....................................១០០ $ ស.រ

៣៨-ឧ.ស ប៊ូ ហោនាង និង ឧ.សិ អ៊ីង វិទ្ធារី និងបុត្រ................១០០ $ ស.រ

៣៩-ឧ.ស ចេក ឃាន - ចេក វឌ្ឍនារី និង ង៉ាន សារិត............១០០ $ ស.រ

៤០ -ឧ.ស ឆៀង ឆេង និង ឧ.សិ ងាន់ មុំ...............................១០០ $ ស.រ

៤១-ឧ.សិ ឆាន់ លួយហ្វន....................................................១០០ $ ស.រ

៤២-ឧ.សិ ស៊ុយ ជាលី ព្រមទាំងកូនចៅ.................................១០០ $ ស.រ

៤៣-ឧ.សិ ម៉ៅ គីមស៊ីន.......................................................១០០ $

៤៤-ឧ.សិ នង សារុន..........................................................១០០ $

៤៥-ឧ.សិ ញ៉ែម ពន្លក និងក្រុមគ្រួសារ.................................. ៨០ $ ស.រ

៤៦-ឧ.សិ នូ សុខុន និង ឧ.សិ អ៊ុង គីមស៊ន............................៧០ $

៤៧-ឧ.សិ ផេង ឈូក...........................................................៦០ $

៤៨-ឧ.សិ ហេង រស់............................................................៦០ $

៤៩-ឧ.សិ ពៅ វ៉ាន់យ៉ា..........................................................៦០ $

៥០-ឧ.សិ ហេង ម៉ុម............................................................៦០ $ ស.រ

៥១-លោកតា ផាត សារ៉ុយ និង លោកតា វ៉ាត់ អម..................៦០ $ ស.រ

៥២-ឧ.សិ ទូច សារ៉េន និង អ្នកស្រី ផន ធារី............................៥៥ $

៥៣-ឧកញ៉ា មហាឧ.សិ ញ៉ឹក ប៊ុនថា និង ឧ.សិ ម៉ែន សុភារី..........៥០ $

៥៤-លោកជំទាវ អ៊ិត សំហេង..............................................៥០ $

៥៥-ឧ.សិ សុវណ្ណរី និង ស្វាមី .................................................៥០ $

៥៦-លោក តាំង ហេងលី និង ជីវ មុយខេង ព្រមទាំងកូនចៅ......៥០ $ ភ.ព

៥៧-អ្នកស្រី ហេង សុធារី ព្រមទាំងបុត្រ.................................៥០ $ ភ.ព

៥៨-ឧ.សិ ឯម ណារី.............................................................៥០ $

៥៩-ឧ.ស សក មានឿន ឧ.សិ ឈីវ ភឿត...............................៥០ $

៦០-ឧ.ស គីប ប្រម ឧ.សិ កែវ លាត ព្រមទាំងបុត្រ..................៥០ $

៦១-ឧ.ស សាន ណៃ ឧ.សិ តាន សេងលី...............................៥០ $

៦២-ឧ.សិ អ៊ិត ស៊ីថៃ.......................................................... ៥០ $

៦៣-ឧ.សិ ហ៊ុយ សុខុន ព្រមទាំងបុត្រ.....................................៥០ $

៦៤-ឧ.សិ សំណាង ស្រីពៅ...................................................៥០ $

៦៥-ឧ.សិ ស៊ំរិទ្ធ ថូ.................................................................៥០ $

៦៦-ឧ.សិ ជា សួន.............................................................. ៥០ $

៦៧-ឧ.សិ អាំង បូរ៉ុម.......................................................... ៥០ $

៦៨-ឧ.សិ គង់ រំ.................................................................៥០ $

៦៩-ឧ.ស អ៊ឹម ហេង ឧ.សិ យែម សុធារី និង បុត្រ......................៥០ $

| | | | |
|---|---|---|---|
| ៧០ | -ព្រះភិក្ខុ ស្រេង សុខា វត្តនិរោធរង្សី | ៥០ $ | |
| ៧១ | -ឧ.សិ ធាវី | ៥០ $ | |
| ៧២ | -ឧ.សិ ជ គាង | ៥០ $ | |
| ៧៣ | -ឧ.សិ កុយ យ៉ាន ព្រមទាំងបុត្រ | ៥០ $ | |
| ៧៤ | -ឧ.ស លឹម កក ឧ.សិ គុយ សុធី | ៥០ $ | ស.រ |
| ៧៥ | -ឧ.ស ចាន់ ភួង ឧ.សិ គីម ម៉ន | ៥០ $ | |
| ៧៦ | -ឧ.សិ ហេង ថូ ព្រមទាំងបុត្រ | ៥០ $ | |
| ៧៧ | -ឧ.សិ នង សុខអឿន | ៥០ $ | |
| ៧៨ | -ឧ.សិ អ៊ុក ស៊ីច័ន្ទ | ៥០ $ | |
| ៧៩ | -ឧ.សិ ឈុន យ៉េន ព្រមទាំងបុត្រ | ៥០ $ | |
| ៨០ | -សាមណេ ឈាង សាមុី | ៥០ $ | ឥណ្ឌា |
| ៨១ | -ឧ.សិ ពេជ្រ សុឃិត | ៥០ $ | |
| ៨២ | -ឧ.សិ ទត់ គីមសៀង ហៅសូត្រ | ៥០ $ | |
| ៨៣ | -ឧ.ស សុខ វ៉ាត និង ភរិយា ព្រមទាំងបុត្រ | ៥០ $ | |
| ៨៤ | -ឧ.សិ ពេជ្រ វុទ្ធី | ៥០ $ | |
| ៨៥ | -ឧ.សិ គី ចន្ធី | ៥០ $ | |
| ៨៦ | -ឧ.សិ ម៉ឹង លន់ | ៥០ $ | |
| ៨៧ | -ឧ.សិ គី ង៉ | ៥០ $ | |
| ៨៨ | -ឧ.សិ អ៊ីន មួយលីន | ៥០ $ | ស.រ |
| ៨៩ | -លោក ហេង ដារិត អ្នកស្រី ឡារី ព្រមទាំងបុត្រ | ៥០ $ | ស.រ |
| ៩០ | -ឧ.សិ អាវ ប៊ួយ ព្រមទាំងបុត្រ | ៥០ $ | ស.រ |
| ៩១ | -ញោម ថូស៊ាក និង ហេង ថូ | ៥០ $ | ស.រ |
| ៩២ | - ចាន់ ថុលថូ | ៥០ $ | ស.រ |
| ៩៣ | -អ្នកស្រី ចរិយា ថូ និង ស្វាមី ព្រមទាំងបុត្រ | ៥០ $ | ស.រ |
| ៩៤ | -អ្នកស្រី ម៉ាក់ ស៊ីថូ និង ស្វាមី ព្រមទាំងបុត្រ | ៥០ $ | ស.រ |
| ៩៥ | -ឧ.សិ ហាន់ ស៊ូលី | ៥០ $ | |
| ៩៦ | -ឧ.សិ ទឹម ហន | ៥០ $ | ស.រ |
| ៩៧ | -ឧ.សិ ស្រុន គីមចេង និង អ្នកស្រី ហួនដាណែត | ៥០ $ | ស.រ |
| ៩៨ | -ឧ.ស នីន ហាក់ និង ឧ.សិ លុយ ចាន់ថន | ៥០ $ | ស.រ |
| ៩៩ | -ឧ.ស ខៀវ ស៊ីណារុន និង ឧ.សិ ស៊ីម បុប្ផ | ៥០ $ | ស.រ |
| ១០០ | -ឧ.សិ សុខ អឿន | ៥០ $ | ស.រ |
| ១០១ | -ឧ.សិ សឹង ធីហន ព្រមទាំងបុត្រ | ៥០ $ | ស.រ |
| ១០២ | -ឧ.សិ ហេង ថូ ព្រមទាំងបុត្រ | ៥០ $ | ស.រ |
| ១០៣ | -ឧ.សិ គីម អាន់ ព្រមទាំងកូនចៅ | ៥០ $ | |
| ១០៤ | -ឧ.សិ អ៊ីង សាន | ៥០ $ | |
| ១០៥ | -ឧ.សិ ឡុង អ៊ីម | ៤០ $ | ស.រ |

| | | | |
|---|---|---|---|
| ១០៦ | -ឧ.សិ អ៊ុល ស៊ីណា | ៤០ $ | ស.រ |
| ១០៧ | -ឧ.សិ ហាច ហឿន | ៤០ $ | ស.រ |
| ១០៨ | -ឧ.សិ Maran Prak and Mr.Jin Wyaff | ៤០ $ | ស.រ |
| ១០៩ | -ឧ.ស ម៉ម ពេញវង់ និង ភរិយា ព្រមទាំងបុត្រ<br>-ឧ.ស ភន់គីមហុង និង ឧ.សិ ឈឹម ឆោម<br>-ឧ.ស សេង ហន និង ឧ.សិ ហ៊ឹម សំបូ | ១០០ $ | |
| ១១០ | -ឧ.សិ តាំង លេខគាវ ហៅតាំងហៀង | ៣០ $ | ស.រ |
| ១១១ | -ឧ.សិ ដួង សារុំ | ៣០ $ | |
| ១១២ | -ឧ.សិ ស៊ូ សុជាតិ | ៣០ $ | |
| ១១៣ | -ឧ.សិ ខៀវ ណាត | ៣០ $ | ស.រ |
| ១១៤ | -ឧ.សិ អៀម វ៉ន និង ឧ.សិ សុក សោរិន | ៣០ $ | ស.រ |
| ១១៥ | -ឧ.សិ ប្លែក ណារុត ព្រមទាំងក្ស័យ និងចៅ | ៣០ $ | |
| ១១៦ | -ឧ.សិ ប្រាក់ សារាយ | ៣០ $ | ស.រ |
| ១១៧ | -ឧ.សិ ហ៊ុន សំអាត | ៣០ $ | |
| ១១៨ | -ឧ.ស ម៉ែន វុីតស្មាន់ឈឿន | ២៥ $ | ស.រ |
| ១១៩ | -ឧ.ស ឡឹក សុន | ២០ $ | ភ.ព |
| ១២០ | -ឧ.សិ ជីវ ស៊ីវហ៊ុយ ព្រមទាំងបុត្រ និងចៅ | ២០ $ | ភ.ព |
| ១២១ | -ឧ.សិ សុខ គ្រុយ ព្រមទាំងបុត្រ | ២០ $ | ភ.ព |
| ១២២ | -ព្រះភិក្ខុ ពេញ សុចន្ទី | ២០ $ | |
| ១២៣ | -ឧ.សិ សុខ ឡាង | ២០ $ | ស.រ |
| ១២៤ | -ឧ.សិ ញ៉ែម សុខវណ្ណារី | ២០ $ | ស.រ |
| ១២៥ | -លោក កុក ហួហុង ឧ.សិ សាមុន ហុង | ២០ $ | ស.រ |
| ១២៦ | -យុវជនគុយ ធារី កញ្ញា សួរតនា | ២០ $ | ស.រ |
| ១២៧ | -ព្រះភិក្ខុ កែវ ចែម វត្តសុវណ្ណគង្គា ព្រៃនប់ | ២០ $ | |
| ១២៨ | -ឧ.សិ ប៉ាង សន | ២០ $ | |
| ១២៩ | -ឧ.សិ លី ឡាញ់ | ២០ $ | |
| ១៣០ | -ឧ.សិ អ៊ុន ពុំ | ២០ $ | |
| ១៣១ | -ឧ.ស ស៊ាន ហ៊ី ឧ.សិ ហាន ហាយ ព្រមទាំងបុត្រ | ២០ $ | |
| ១៣២ | -ឧ.ស អាវ ស្រ៊ុន | ២០ $ | ស.រ |
| ១៣៣ | -ឧ.សិ ពៅ សាវណ្ណ | ២០ $ | ស.រ |
| ១៣៤ | -ឧ.ស ពៅ វ៉ើន ឧ.សិ ឡាច យៀម | ២០ $ | ស.រ |
| ១៣៥ | -លោក ម៉ុត វរិនសុក | ២០ $ | ស.រ |
| ១៣៦ | -ឧ.សិ ញ៉ែម ពន្លក | ២០ $ | ស.រ |
| ១៣៧ | -ឧ.សិ ហុក តាំងចាន់ | ២០ $ | ស.រ |
| ១៣៨ | -ឧ.សិ អ៊ឹង ប៊ូតាន់ | ២០ $ | ស.រ |
| ១៣៩ | -អ្នកស្រីហាក់ ស៊ូលីម និង ស្វាមី ព្រមទាំងកូនចៅ | ២០ $ | |

១៤០ -ឧ.សិ ភួយ គីមឈន ព្រមទាំងកូន និងចៅ.................... ២០ $

១៤១ -ឧ.សិ ហ៊ួយ សុខខេង ព្រមទាំងកូន និង ចៅ.................. ២០ $

១៤២ -អ្នកស្រី ហួយ គីមឈាង និង ស្វាមី ព្រមទាំងកូនចៅ......២០ $

១៤៣ -ឧ.សិ  កុល ចិន្តា....................................................២០ $

១៤៤ -  ប៉ាត់ ប៊ុនឆប និង ហ៊ីង វណ្ណា..............................២០ $ ស.រ

១៤៥ -ឧ.ស ម៉ាក់ អ៊ុយ និង ឧ.សិ ថថហ៊ុន យឹម.......................២០ $ ស.រ

១៤៦ -លោក ឃុត សាវឿន និង អ្នកស្រី សុមន្តា និងបុត្រ........២០ $ ស.រ

១៤៧ -ឧ.ស ព្រះ ឈាង..................................................... ២០ $ ស.រ

១៤៨ -ឧ.សិ ថោង សៀន...................................................២០ $ ស.រ

១៤៩ -អ្នកស្រី គង់ ប៊ុនថៃ ព្រមទាំងបុត្រ...............................២០ $ ស.រ

១៥០ -អ្នកស្រី មួង សារ៉ាត់..................................................២០ $ ស.រ

១៥១ -ឧ.ស តែម និង កូន វិបុល.........................................១៥ $

១៥២ -កញ្ញា ឆុង សុភាន....................................................៥ម៉ឺនរៀល ភ.ព

១៥៣ -លោក ឡៅ សៀកហេង និង ទា អ៊ីអ៊ីង.......................៥ម៉ឺនរៀល ភ.ព

១៥៤ -អ.ស្រី ម៉ម បុប្ផា.....................................................១០ $ ភ.ព

១៥៥ -ឧ.សិ សុខ អេង.......................................................១០ $ ភ.ព

១៥៦ -ឧ.សិ អ៊ា គីមយូ ....................................................១០ $ ភ.ព

១៥៧ -ឧ.ស ជ្រា ប៉េង ឧ.សិ ត្រិត ត្រឹម.................................១០ $ ភ.ព

១៥៨ -ឧ.សិ សួន សុ.........................................................១០ $ ភ.ព

១៥៩ -ឧ.សិ ហេង ស៊ីវខេង................................................១០ $ ភ.ព

១៦០ -ឧ.សិ តូ លាម.........................................................១០ $ ស.រ

១៦១ -ឧ.សិ អ៊ីន សាលើក ................................................១០ $ ស.រ

១៦២ -លោក ព្យប និង ឧបាសិកា ហុងគីមហួរ......................១០ $ ស.រ

១៦៣ -លោក លី សៀវឃន់ និង ឧបាសិកា គីម ហាន់.............១០ $ ស.រ

១៦៤ -អ្នកស្រី លឹម សុគុន.................................................១០ $ ស.រ

១៦៥ -ឧ.សិ ប៉ាត សុខខឿន................................................១០ $

១៦៦ -ព្រះភិក្ខុ វ៉ាន់ សុខគីម............................................១០ $

១៦៧ -ឧ.ស យ៉ោក ឡោម.................................................១០ $

១៦៨ -ឧ.សិ ប៉ាង កៅនី.....................................................១០ $

១៦៩ -ឧ.សិ សោ គីមសៀ.................................................១០ $

១៧០ -ឧ.សិ ហ៊ី គា ព្រមទាំងបុត្រ........................................១០ $

១៧១ -ឧ.សិ ឆេង បូរ៉ាវី ព្រមទាំងបុត្រ................................១០ $

១៧២ -ព្រះភិក្ខុ អ៊ូច សុខា វត្តពោធិវើយ ស្រុកស្អាង.............១០ $

១៧៣ -ឧ.សិ ជៀក ស៊ាងលី ព្រមទាំងបុត្រ............................១០ $

១៧៤ -លោក ហ៊ួយ ងួនហេង និង ភរិយា ព្រមទាំងកូនចៅ.......១០ $

១៧៥ -លោក ភួយ ជា និង ភរិយា ព្រមទាំងកូនចៅ................១០ $

១៧៦ -ឧ.ស យ៉ាំ ស្រេន និង ភរិយា ព្រមទាំងកូនចៅ...............១០ $

១៧៧ -ឧ.សិ តាន់ គីមហៀក និង ស្វាមី ព្រមទាំងបុត្រ.............១០ $

១៧៨ -ឧ.សិ ខៀវ ខេមរេត.................................................១០ $

១៧៩ -  ជីវ ចាន់សុភី.................................................១០ $

១៨០ -  ជីវ ចាន់សុភ័ណ.............................................១០ $

១៨១ -  ជីវ ចាន់សុធា................................................១០ $

១៨២ -  ជីវ ចាន់សុភាព..............................................១០ $

១៨៣ -  ជីវ ចាន់សុខសាន...........................................១០ $

១៨៤ -ឧ.សិ ស៊ុន វូចលៀង.................................................១០ $

១៨៥ -ឧ.សិ ជូន នាង និង ស្វាមី ព្រមទាំងបុត្រ.....................១០ $

១៨៦ -ឧ.សិ សូវីឡា ព្រមទាំងបុត្រ......................................១០ $

១៨៧ -អ្នកស្រី ជឹម ប៊ុនចិន្តា ព្រមទាំងកូនចៅ........................១០ $

១៨៨ -ឧ.សិ សុខ ម៉ុម........................................................១០ $

១៨៩ -ឧ.សិ ជា ប៉ាត..........................................................១០ $

១៩០ -ឧ.សិ ដួង គិមស៊ុន ព្រមទាំងកូនចៅ............................១០ $

១៩១ -អ្នកស្រី ស្រឹង ចំរើន..................................................១០ $ ស.រ

១៩២ -អ្នកស្រី គី ជី............................................................១០ $ ស.រ

១៩៣ -ឧ.សិ គីម ពៅ........................................................៥ $

១៩៤ -ឧ.សិ ង៉ែត សុវត្ថិ....................................................៥ $

១៩៥ -ឧ.សិ អឹម អឹម........................................................៥ $

១៩៦ -ឧ.សិ អ៊ុក អៀម.....................................................៥ $

១៩៧ -ឧ.ស សុន តេង.......................................................៥ $

១៩៨ -ឧ.ស ឆេង សុធន និង ឧបាសិកា អ៊ុក ស៊ីណាត...............៥ $

១៩៩ -ឧ.ស ប្រោញ ជ្រា...................................................៥ $

២០០ -ឧ.សិ ជាស ស៊ីណាត.................................................៥ $

២០១ -ឧ.សិ ឡឹក សាត.......................................................៥ $

២០២ -ឧ.សិ លន់ កល្យាណ................................................ ៥ $

២០៣ -ឧ.សិ លឹម ចន្ថន ..................................................៥ $

២០៤ -ឧ.សិ ជា ផល្លា ព្រមទាំងបុត្រ.................................... ៥ $

២០៥ -ឧ.សិ លី យក់ខេន ព្រមទាំងបុត្រ.............................. ៥ $

២០៦ -ឧ.សិ លឹម ផុងឈីវ និង ឧបាសិកា អឿវ សារុន............ ៥ $

២០៧ -ឧ.សិ គុជ បូរី.........................................................៥ $

២០៨ -ឧ.សិ សេង យ៉ី........................................................៥ $

២០៩ -ឧ.សិ អ៊ីង បោតាន់....................................................៥ $ ស.រ

២១០ -ឧ.សិ គួយ ឡៃងិន....................................................៥ $ ស.រ

២១១ -ឧ.សិ អ៊ុន យឿង.................................................... ៥ $ ស.រ

២១២ -កញ្ញា ឆេង ផល.............................................៥ $
២១៣ -ឧ.សិ ប៉ោ រ៉ារី.................................................៥ $
២១៤ -លោក អ៊ាន ជីវ៉ា និង ភរិយា ព្រមទាំងបុត្រ..........៥ $
២១៥ -លោក អាំង ធាចាន់ និង ភរិយា ព្រមទាំងបុត្រ......៥ $
២១៦ -លោក ម៉ៅ មូវ និង អ.គ្រូ ទីវ សុមាលី................៥ $
២១៧ -ឧ.សិ ចាប ស៊ីណា...........................................៥ $
២១៨ -ឧ.សិ ស្វូ ទីម.................................................៥ $
២១៩ -ឧ.សិ អ៊ី ណារិន...............................................៥ $
២២០ -ឧ.សិ ឃី ងីម...................................................៥ $
២២១ -ឧ.សិ ឡូ សាយគាវ.........................................៥ $
២២២ -ឧ.សិ ឧក ញ៉ែម...............................................៥ $
២២៣ -ឧ.សិ សេន ឡៃ................................................៥ $
២២៤ -ឧ.សិ ប៊ុ ហ៊ុយជូ................................................៥ $
២២៥ -ឧ.សិ ប៉ូវ ស៊ីថា.................................................៥ $
២២៦ -ឧ.សិ សៃ ហៀង..............................................៥ $
២២៧ -ឧ.សិ ចេង ហ៊ុយហ៊ួន.......................................៥ $
២២៨ -ឧ.សិ សុខ សាវរី..............................................៥ $
២២៩ -អ្នកស្រី សួង ផាន់ណា និង ស្វាមី ព្រមទាំងបុត្រ...... ៥ $
២៣០ -ឧ.សិ ពេជ្រ សុផារី និង ស្វាមី ព្រមទាំងបុត្រ..........៥ $
២៣១ -អ្នកស្រី ពេជ្រ ស៊ីថា និង ស្វាមី ព្រមទាំងបុត្រ........៥ $
២៣២ -ឧ.សិ ឈីវ ពៅ................................................ ៥ $
២៣៣ -ឧ.សិ ញ៉ែម យ៉ម...............................................៥ $
២៣៤ -ឧ.សិ ស៊ឹង ចាន់ថន............................................៥ $
២៣៥ -ឧ.សិ កន យឿត..............................................៥ $
២៣៦ -ឧ.សិ ខេង យ៉ុន...............................................៥ $
២៣៧ -ឧ.សិ ព្រះ ស៊ីប................................................. ៥ $
២៣៨ -អ្នកគ្រូ សុន ញ៉ាញ់...........................................៥ $
២៣៩ -ឧ.សិ អាង គា ព្រមទាំងបុត្រ.............................៣ $
២៤០ -ទាយិកា គីម សារិន និង កញ្ញា ឌឹម បុប្ផា...............១ម៉ឺនរៀល
២៤១ -អ្នកគ្រូ សុន ភ័ក្រ............................................១ម៉ឺនរៀល
២៤២ -ឧ.សិ ប៉ែន វ៉ន ព្រមទាំងបុត្រ.............................១ម៉ឺនរៀល
២៤៣ -កុមារា ច័ន្ទ និង ច័ន្ទ សុធី...................................៧ពាន់រៀល
២៤៤ -ឧ.សិ ឃឹម សារ៉ាន់........................................... ១ $
២៤៥ -ឧ.សិ ហ៊ឹម សុវណ្ណ............................................១ $
២៤៦ -ឧ.សិ ប៊ុច ពៅ ព្រមទាំងបុត្រ............................ ១ $

(សូមអភ័យទោសចំពោះការបាត់ឈ្មោះ និងរូបភាពក្នុងការចូលរួមបោះពុម្ពសៀវភៅ)





លោក ប៊ូ សារិម អ្នករចនារូបភាព


MP Printing House
រោងពុម្ព ម៉ៅ ផុន (ពុយ)
MAO PHON (PUY) PRINTING HOUSE
Tel : 077 777 800 / 017 581 582
E-mail : phonmao@phonmao.com
Website : www.phonmao.com

# រូបភាពពិធីបុណ្យឆ្លងព្រះគន្ធកុដិ សៀមរាប ព.ស.២៥៥១














ព្រះបដិមាចង្កូមកែវ





















# ពុទ្ធស្ថានទាំងបួនកន្លែង















ដំណើរធម្មយាត្រាលើកទីបួនរបស់លោកគ្រូ

ធម្មាចារ្យ **កែវ វិមុត្ត** និង ពុទ្ធបរិស័ទ នៅឥណ្ឌា-នេប៉ាល់ ព.ស.២៥៥៣